ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

# គោលនយោបាយជាតិ
# ស្តីពី
# សកម្មភាពមីន ឆ្នាំ២០២៦-២០៣៥

បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ
នាថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២៦

# បុព្វកថា

ប្រទេសកម្ពុជាបានឆ្លងកាត់សង្គ្រាមក្នុងតំបន់និងសង្គ្រាមស៊ីវិល ចាប់ពីដើមទសវត្សឆ្នាំ១៩៦០ រហូតដល់ចុងឆ្នាំ១៩៩៨ ទើបទទួលបានសន្តិភាពពេញលេញទូទាំងប្រទេស។ សង្គ្រាមនេះ បានបំផ្លិចបំផ្លាញជាតិស្ទើរទាំងស្រុងដែលបានបន្សល់ទុកនូវផលប៉ះពាល់ដ៏ធ្ងន់ធ្ងរពីគ្រាប់មីននិងសំណល់ជាតិផ្ទុះពីសង្គ្រាម ដោយគិតចាប់តាំងពីឆ្នាំ១៩៧៩មក បានបណ្តាលឱ្យមានអ្នកស្លាប់និងរបួស ជាង៦៥ ០០០នាក់។ ទោះបីជា អត្រាគ្រោះថ្នាក់ប្រចាំឆ្នាំមានការថយចុះគួរឱ្យកត់សម្គាល់ក្តី ក៏ការគំរាមកំហែងទាំងនេះ នៅតែជាឧបសគ្គដ៏ធំចំពោះការអភិវឌ្ឍសេដ្ឋកិច្ច ជាពិសេសនៅតំបន់ជនបទ។

ក្រោមការយកចិត្តទុកដាក់និងគំនិតផ្តួចផ្តើមដ៏ខ្ពង់ខ្ពស់បំផុតរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** អតីតនាយករដ្ឋមន្ត្រី អតីតប្រធានអាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីននិងសង្គ្រោះជនពិការដោយសារមីន ជាបិតាស្ថាបនិក និងជាប្រតិបត្តិករបេសកកម្មស្វែងរកសន្តិភាពនិងផ្សះផ្សាជាតិ សកម្មភាពមីនមនុស្សធម៌កម្ពុជា បានចាប់ផ្តើមក្នុងឆ្នាំ១៩៩២ ដើម្បីសម្រួលដល់មាតុភូមិនិវត្តន៍របស់ជនភៀសខ្លួនដោយសារសង្គ្រាម និងការពារប្រជាពលរដ្ឋពីគ្រោះថ្នាក់ដោយសារមីននិងសំណល់ជាតិផ្ទុះពីសង្គ្រាម។

តាមរយៈនយោបាយ «**ឈ្នះ ឈ្នះ**» របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រទេសកម្ពុជាបានបញ្ចប់ទាំងស្រុងនូវសង្គ្រាមស៊ីវិលដ៏រ៉ាំរ៉ៃ ដែលបានអូសបន្លាយជិត៣ទសវត្ស ដោយគ្មានការបង្ហូរឈាមនិងគ្មានអ្នករងគ្រោះ ហើយបាននាំមកនូវសុវត្ថិភាព សន្តិភាពពេញលេញ ធ្វើឱ្យមានឯកភាពជាតិ ការបង្រួបបង្រួមជាតិ ដែលជាគ្រឹះដល់ការអភិវឌ្ឍលើគ្រប់វិស័យ។ សន្តិភាពក៏បានក្លាយជាមូលដ្ឋានយ៉ាងសំខាន់ដល់ការពង្រីកប្រតិបត្តិការបោសសម្អាតមីននិងសំណល់ជាតិផ្ទុះពីសង្គ្រាម ដែលជាឃាតករលាក់មុខ សម្លាប់ និងបង្កទុក្ខវេទនាដល់ប្រជាពលរដ្ឋស្លូតត្រង់ជាច្រើនម៉ឺននាក់ និងជារនាំងដល់ការអភិវឌ្ឍសេដ្ឋកិច្ច សង្គម ជាពិសេសនៅតាមទីជនបទ។

ពេលនោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** បានសម្រេចដាក់សកម្មភាពមីនជាស្នូលនៃការអភិវឌ្ឍ ដោយបានបញ្ចូលទៅក្នុងយុទ្ធសាស្ត្រត្រីកោណនិងយុទ្ធសាស្ត្រចតុកោណទាំង៤ដំណាក់កាលរបស់រាជរដ្ឋាភិបាល និងឈានដល់ការដាក់ចេញនូវផែនការយុទ្ធសាស្ត្រជាតិសកម្មភាពមីនជាបន្តបន្ទាប់ ដែលជាលទ្ធផលកម្ពុជាសម្រេចបានសមិទ្ធផលសកម្មភាពមីនគួរឱ្យកត់សម្គាល់ ដោយបានប្រែក្លាយដីមានមីននិងសំណល់ជាតិផ្ទុះពីសង្គ្រាមជាច្រើនម៉ឺនហិកតា ទៅជាដីមានសុវត្ថិភាព និងបានប្រគល់ជូនសហគមន៍ដើម្បីប្រើប្រាស់សម្រាប់វិស័យកសិកម្ម ហេដ្ឋារចនាសម្ព័ន្ធ និងការអភិវឌ្ឍនានា។ អត្រានៃអ្នករងគ្រោះដោយសារមីននិងសំណល់ជាតិផ្ទុះពីសង្គ្រាម បានថយចុះពីជាង៤ ០០០នាក់ក្នុងមួយឆ្នាំ ក្នុងទសវត្សឆ្នាំ១៩៩០ មកត្រឹមក្រោម១០០នាក់ក្នុងមួយឆ្នាំ ក្នុងរយៈពេល១០ឆ្នាំចុងក្រោយនេះ។

ប្រទេសកម្ពុជាបានឈានមុខនិងដើរតួសំខាន់ក្នុងសកម្មភាពមីនសកល ដោយបានចែករំលែកបទពិសោធនិងជំនាញរបស់ខ្លួនទៅកាន់ប្រទេសផ្សេងទៀតដែលរងគ្រោះដោយសារមីននិងសំណល់ជាតិផ្ទុះពីសង្គ្រាម ក៏ដូចជាតាមរយៈការចូលរួមបោសសម្អាតមីនក្រោមឆត្ររបស់អង្គការសហប្រជាជាតិ តាំងពីឆ្នាំ២០០៦។ ជាបន្តបន្ទាប់ប្រទេសកម្ពុជាទទួលបានទំនុកចិត្តជ្រើសតាំងដោយរដ្ឋភាគីអនុសញ្ញាអូតាវ៉ា ធ្វើជាប្រធានអនុសញ្ញាចំនួនពីរលើកគឺកិច្ចប្រជុំរដ្ឋភាគីអនុសញ្ញាលើកទី១១ ក្នុងឆ្នាំ២០១១ និងសន្និសីទត្រួតពិនិត្យឡើងវិញលើកទី៥ ឬ «កិច្ចប្រជុំកំពូលសៀមរាប អង្គរ ស្តីពីពិភពលោកមួយដែលគ្មានមីន» ក្នុងឆ្នាំ២០២៤។ ជាមួយគ្នានេះ ប្រទេសកម្ពុជាត្រូវបាន

ទទួលស្គាល់ថាជារដ្ឋភាគីអនុសញ្ញាអូតាវ៉ា ដែលបានប្រកាន់ខ្ជាប់ទៅនឹងគោលការណ៍និងគោរពតាមបទដ្ឋាននៃអនុសញ្ញាអូតាវ៉ា។

ជាមួយនឹងសមិទ្ធផលជាទីកត់សម្គាល់នេះ ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំសូមថ្លែងអំណរគុណ និងវាយតម្លៃខ្ពស់ចំពោះគ្រប់ភាគីពាក់ព័ន្ធ រួមមានអាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីននិងសង្គ្រោះជនពិការដោយសារមីន ក្រសួង ស្ថាប័ន ប្រតិបត្តិករជាតិ អន្តរជាតិ ប្រទេសផ្តល់ជំនួយ ដៃគូអភិវឌ្ឍ វិស័យឯកជន អង្គការជាតិអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងសប្បុរសជនទាំងឡាយ ដែលបានចូលរួមទាំងជំនួយហិរញ្ញវត្ថុ ទាំងជំនួយបច្ចេកទេស ក្នុងបុព្វហេតុសកម្មភាពមីនមនុស្សធម៌នៅប្រទេសកម្ពុជា។

ទោះបីជាវិស័យសកម្មភាពមីនមានវឌ្ឍនភាពគួរឱ្យកោតស្ញប់ស្ញែងបែបនេះក៏ដោយ ប្រទេសកម្ពុជានៅតែបន្តប្រឈមមុខនឹងគ្រោះថ្នាក់ដែលបន្សល់ទុកពីអតីតកាល គឺគ្រាប់មីននិងសំណល់ជាតិផ្ទុះពីសង្គ្រាមរាប់លានគ្រាប់ ដែលជាឃាតករលាក់មុខ បន្តគំរាមកំហែងដល់សុខសុវត្ថិភាព និងជាឧបសគ្គរាំងស្ទះដល់ការអភិវឌ្ឍប្រទេស។ បរិការណ៍នេះទាមទារនូវវិធីសាស្ត្រនិងយុទ្ធសាស្ត្រថ្មីមួយប្រកបដោយភាពច្នៃប្រឌិតនិងនវានុវត្តន៍។ ដើម្បីសម្រេចគោលដៅនេះ រាជរដ្ឋាភិបាលបានកំណត់វិស័យសកម្មភាពមីនជាអាទិភាពមួយក្នុង **យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល នីតិកាលទី៧នៃរដ្ឋសភា**។

ក្នុងន័យនេះ គោលនយោបាយជាតិស្តីពីសកម្មភាពមីន ឆ្នាំ២០២៦-២០៣៥ ត្រូវបានរៀបចំឡើងក្រោមការដឹកនាំរបស់អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីននិងសង្គ្រោះជនពិការដោយសារមីន តាមរយៈការពិគ្រោះយោបល់យ៉ាងទូលំទូលាយជាមួយគ្រប់ភាគីពាក់ព័ន្ធ ដើម្បីសម្រេច ចក្ខុវិស័យ «**ប្រទេសកម្ពុជារួចផុតពីផលប៉ះពាល់នៃយុទ្ធភណ្ឌគ្រឿងផ្ទុះ ធ្វើឱ្យជីវភាពរស់នៅប្រកបដោយចីរភាព ជំរុញសន្តិភាព ស្ថិរភាព និងការអភិវឌ្ឍ**»។ គោលនយោបាយជាតិនេះ គឺជាផែនទីបង្ហាញផ្លូវឆ្ពោះទៅសម្រេចការបញ្ចប់ការបោសសម្អាតមីននិងគ្រាប់បែកចង្កោមដែលបានដឹងទាំងអស់ និងសំណល់ជាតិផ្ទុះពីសង្គ្រាមផ្សេងទៀតដែលបង្កការគំរាមកំហែងខ្ពស់ ហើយពង្រឹងសមត្ថភាពជាតិ ដើម្បីត្រៀមលក្ខណៈសម្រាប់ដំណាក់កាលគ្រប់គ្រងសំណល់យុទ្ធភណ្ឌគ្រឿងផ្ទុះដែលនៅសេសសល់។

ជាមួយគ្នានេះ ប្រទេសកម្ពុជានឹងនៅបន្តប្រកាន់ខ្ជាប់នូវគោលការណ៍និងគោរពតាមបទដ្ឋាននៃអនុសញ្ញាអូតាវ៉ា បន្តចូលរួមសកម្មក្នុងកិច្ចការសកលភាវូបនីយកម្មនៃអនុសញ្ញាអូតាវ៉ា និងបន្តចែករំលែកបទពិសោធចំណេះដឹង និងជំនាញរបស់ខ្លួនទៅកាន់ប្រទេសរងគ្រោះដទៃទៀត ដើម្បីចូលរួមលុបបំបាត់សោកនាដកម្មបង្កឡើងដោយមីននិងសំណល់ជាតិផ្ទុះពីសង្គ្រាម។ ប្រទេសកម្ពុជាមិនចង់ឃើញប្រទេសឬជាតិសាសន៍ណាមួយទទួលរងគ្រោះដូចប្រទេសកម្ពុជានោះឡើយ។

ខ្ញុំសូមកោតសរសើរនិងវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ **ឯកឧត្តមបណ្ឌិត លី ធុជ** ទេសរដ្ឋមន្ត្រីអនុប្រធានទី១ និងថ្នាក់ដឹកនាំ មន្ត្រី បុគ្គលិកគ្រប់ជាន់ថ្នាក់នៃអាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីននិងសង្គ្រោះជនពិការដោយសារមីន ព្រមទាំងសូមថ្លែងអំណរគុណដល់គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍនិងប្រតិបត្តិករទាំងអស់ ដែលបានរួមចំណែកយ៉ាងសកម្មក្នុងការផ្តល់ធាតុចូលរៀបចំឯកសារគោលនយោបាយដ៏មានសារៈសំខាន់នេះ។

ខ្ញុំជឿជាក់យ៉ាងមុតមាំថា ក្រោមកិច្ចខិតខំប្រឹងប្រែងនិងការប្តេជ្ញាចិត្តរួមគ្នារបស់យើង ប្រទេសកម្ពុជានឹងរួចផុតពីផលប៉ះពាល់ដោយសារមីននិងសំណល់ជាតិផ្ទុះពីសង្គ្រាម ដែលជំរុញដល់ការរក្សាសន្តិភាព ស្ថិរភាព

និងការអភិវឌ្ឍប្រកបដោយចីរភាព ហើយនឹងចូលរួមចំណែកសំខាន់ក្នុងការសម្រេចគោលដៅកាត់បន្ថយភាពក្រីក្រ ជំរុញការអភិវឌ្ឍសេដ្ឋកិច្ច ឆ្ពោះទៅកាន់ចក្ខុវិស័យប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសដែលមានចំណូលខ្ពស់នៅឆ្នាំ២០៥០។

ថ្ងៃសុក្រ ៨កើត ខែពិសាខ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២៦

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

# បញ្ជីពាក្យកាត់

| | | |
|---|---|---|
| ក.ប.ម. | : | ក្រុមការងារបច្ចេកទេសចម្រុះរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍលើវិស័យមីន |
| គ.ជ.ស.ម. | : | គោលនយោបាយជាតិស្តីពីសកម្មភាពមីន |
| គ.ស.ម. | : | គណៈកម្មាធិការសម្របសម្រួលសកម្មភាពមីន |
| ផ.យ.ជ.ម. | : | ផែនការយុទ្ធសាស្ត្រជាតិសកម្មភាពមីន |
| ផ.យ.អ.ជ. | : | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ |
| ស.ផ.ស. | : | សំណល់ជាតិផ្ទុះពីសង្គ្រាម |
| អ.ហ.ផ.ម. | : | អនុសញ្ញាស្តីពីការហាមការប្រើប្រាស់ ការរក្សាទុក ការផលិត និងការផ្ទេរគ្រាប់មីនប្រឆាំងមនុស្ស និងការបំផ្លាញគ្រាប់មីន |
| CCW | : | The Convention on Certain Conventional Weapons<br>អនុសញ្ញាស្តីពីសព្វាវុធធម្មតា |

# មាតិកា


**អារម្ភកថា** ........ i

**បញ្ជីពាក្យកាត់** ........ iv

**១- សេចក្តីផ្តើម** ........ ១

**២- ចក្ខុវិស័យ** ........ ៤

**៣- គោលបំណងនិងគោលដៅ** ........ ៤

**៤- យុទ្ធសាស្ត្រ** ........ ៥

**៥- ផែនការសកម្មភាព** ........ ១៣

 ៥.១- ការបង្កើតយន្តការ ........ ១៣

 ៥.២- ការបង្កើតក្របខ័ណ្ឌគតិយុត្ត ........ ១៤

 ៥.៣- ការគាំទ្រហិរញ្ញវត្ថុ ........ ១៤

 ៥.៤- ការបណ្តុះបណ្តាលធនធានមនុស្ស ........ ១៥

 ៥.៥- ដំណើរការអនុវត្តគម្រោង ........ ១៥

**៦- ការតាមដានត្រួតពិនិត្យនិងការវាយតម្លៃ** ........ ១៧

**៧- សេចក្តីសន្និដ្ឋាន** ........ ១៨

**សន្ទានុក្រម** ........ ១៩

## ១- សេចក្តីផ្តើម

ជម្លោះក្នុងប្រទេសនិងក្នុងតំបន់ ដែលបានអូសបន្លាយរយៈពេលយ៉ាងយូរ ចាប់ផ្តើមពីដើមទសវត្សឆ្នាំ១៩៦០ រហូតដល់ចុងឆ្នាំ១៩៩៨ បានបន្សល់ទុកនូវបញ្ហាមីននិងសំណល់ជាតិផ្ទុះពីសង្គ្រាមធ្ងន់ធ្ងរនៅប្រទេសកម្ពុជា ព្រមទាំងបានធ្វើឱ្យប្រទេសកម្ពុជាក្លាយជាប្រទេសមួយក្នុងចំណោមប្រទេសដែលមានមីននិងសំណល់ជាតិផ្ទុះពីសង្គ្រាម ច្រើនជាងគេនៅលើពិភពលោក និងបានបង្កគ្រោះថ្នាក់ដល់មនុស្សប្រមាណជាង ៦៥ ០០០នាក់ រាប់ចាប់ពីឆ្នាំ១៩៧៩មក។

កម្មវិធីសកម្មភាពមីនមនុស្សធម៌នៅប្រទេសកម្ពុជា បានចាប់ផ្តើមនៅក្នុងឆ្នាំ១៩៩២ ក្នុងគោលបំណងរំដោះផ្ទៃដីដែលមានមីននិងស.ផ.ស.។ គិតត្រឹមខែធ្នូ ឆ្នាំ២០២៥ ប្រទេសកម្ពុជាបានបោសសម្អាតនិងរំដោះផ្ទៃដីមានមីននិងស.ផ.ស. សរុបចំនួន៣ ៥៤១ គីឡូម៉ែត្រការ៉េ ក្នុងនោះបានរកឃើញនិងកម្ទេចចោលមីនប្រឆាំងមនុស្សចំនួន១ ២០៧ ១៣៣គ្រាប់ មីនប្រឆាំងរថក្រោះចំនួន២៦ ៧០០គ្រាប់និងស.ផ.ស. ចំនួន៣ ២៤៤ ១៧៨គ្រាប់។ ក្នុងឆ្នាំ២០២២ និងឆ្នាំ២០២៣ ប្រទេសកម្ពុជាបានបោសសម្អាតនិងរំដោះផ្ទៃដីមានមីននិងស.ផ.ស. ចំនួន៦៩៥ គីឡូម៉ែត្រការ៉េ ដែលសមិទ្ធផលគួរឱ្យកត់សម្គាល់នេះអាចសម្រេចបានដោយសារការដាក់ចេញនូវយុទ្ធសាស្ត្រកៀរគរធនធានប្រកបដោយប្រសិទ្ធភាពនិងនវានុវត្តន៍ ដែលក្នុងនោះរួមបញ្ចូលនូវ **គម្រោងសម្តេចតេជោសម្រាប់សកម្មភាពមីន** និងការចូលរួមចំណែកយ៉ាងសំខាន់ពីវិស័យឯកជន។

សមិទ្ធផលទាំងនេះ បានឆ្លុះបញ្ចាំងពីប្រសិទ្ធភាពនិងការប្តេជ្ញាចិត្តខ្ពស់នៅក្នុងកិច្ចខិតខំប្រឹងប្រែងបោសសម្អាតមីនរបស់រាជរដ្ឋាភិបាលកម្ពុជា ដៃគូអភិវឌ្ឍ វិស័យឯកជន អង្គការមិនមែនរដ្ឋាភិបាល សប្បុរសជន និងប្រតិបត្តិករបោសសម្អាតមីន រួមមានបញ្ជាការដ្ឋានកងទ័ពជើងគោក មជ្ឈមណ្ឌលជាតិគ្រប់គ្រងកងកម្លាំងរក្សាសន្តិភាព បោសសម្អាតមីននិងកាកសំណល់សង្គ្រាម មជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា អង្គការហេឡូត្រាស្ត អង្គការម៉ែក អង្គការជំនួយនៃប្រជាពលរដ្ឋន័រវែស អង្គការអាប៉ូប៉ូ និងអង្គការដោះមីនកម្ពុជា។ ទោះជាយ៉ាងនេះក្តីនៅពេលប្រតិបត្តិការបោសសម្អាតមីនឈានចូលទៅជិតតំបន់ព្រំដែនកម្ពុជា ថៃ ចម្ការមីនថ្មីៗត្រូវបានរកឃើញជាបន្តបន្ទាប់ ជាពិសេសនៅតាមតំបន់ដាច់ស្រយាលនិងព្រៃជ្រៅដែលមិនទាន់ស្រាវជ្រាវ។ អាស្រ័យហេតុនេះ ទាមទារឱ្យប្រទេសកម្ពុជាពង្រីកវិសាលភាពនៃការស្រាវជ្រាវ ដើម្បីដឹងច្បាស់ពីទំហំពិតប្រាកដនៃតំបន់ដែលមានការគំរាមកំហែង។ បន្ថែមលើនេះ ទាមទារឱ្យប្រទេសកម្ពុជាដាក់ចេញនូវគោលនយោបាយគ្រប់ជ្រុងជ្រោយ ដោយផ្អែកលើបទពិសោធ និងកិច្ចខិតខំប្រឹងប្រែងកន្លងមក ដើម្បីឆ្លើយតបនឹងតំបន់គំរាមកំហែងដែលបានរកឃើញថ្មីៗ និងការគ្រប់គ្រងសំណល់យុទ្ធភណ្ឌគ្រឿងផ្ទុះដែលនៅសេសសល់ ប្រកបដោយប្រសិទ្ធភាព និងចីរភាព។

ដោយយោងតាមប្រព័ន្ធទិន្នន័យជាតិ គិតត្រឹមខែធ្នូ ឆ្នាំ២០២៥ ផ្ទៃដីមានមីននិងស.ផ.ស. ដែលនៅសេសសល់នៅក្នុងប្រទេសកម្ពុជា មានចំនួន១ ៧៤៩គីឡូម៉ែត្រការ៉េ ក្នុងនោះ៖

- ផ្ទៃដីមីនចំនួន៥៥៧គីឡូម៉ែត្រការ៉េ
- ផ្ទៃដីគ្រាប់បែកចង្កោមចំនួន៦៦៣គីឡូម៉ែត្រការ៉េ
- ផ្ទៃដីស.ផ.ស.ផ្សេងទៀតចំនួន៥២៩គីឡូម៉ែត្រការ៉េ។

ទិន្នន័យខាងលើនេះមិនទាន់រាប់បញ្ចូលលទ្ធផលពេញលេញនៃការស្រាវជ្រាវចម្ការមីននិងស.ផ.ស. តាមបណ្តោយព្រំដែនកម្ពុជា ថៃ និងការស្រាវជ្រាវគ្រាប់បែកចង្កោមនិងគ្រាប់បែកទម្លាក់ ដែលនឹងត្រូវធ្វើបច្ចុប្បន្នកម្មក្នុងផែនការអនុវត្តសកម្មភាព។

ការដោះស្រាយបញ្ហាមីននិងស.ផ.ស. ចូលរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ច សង្គម សមភាពយេនឌ័រ បរិយាបន្នពិការភាព ការកាត់បន្ថយភាពក្រីក្រ និងចីរភាពបរិស្ថាន។ ក្នុងន័យនេះ សកម្មភាពមីននៅកម្ពុជាបាន អនុវត្តស្របតាមគោលដៅអភិវឌ្ឍន៍ជាតិ ដូចមានចែងក្នុងកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា សម្រាប់ការកសាងនិងការការពារមាតុភូមិ ឆ្នាំ២០២៣-២០២៨ និងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល នីតិកាលទី៧នៃរដ្ឋសភា។ ការប្តេជ្ញាចិត្តរបស់ប្រទេសកម្ពុជាក្នុងសកម្មភាពមីន បានឆ្លុះបញ្ចាំងពីឆន្ទៈក្នុងការចូលរួមស្វែងរកសន្តិភាពនិងវិបុលភាពសម្រាប់សកលលោក សំដៅធានាសុខសុវត្ថិភាព ជូនប្រជាជននិងចូលរួមក្នុងកិច្ចខិតខំប្រឹងប្រែងជាមួយសហគមន៍អន្តរជាតិ ដើម្បីលុបបំបាត់មីននិងស.ផ.ស. ឱ្យអស់ពីពិភពលោក។

ដោយសារសកម្មភាពមីនមានសក្តានុពលបង្កើតឱកាសសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព និងបរិយាបន្នទូទាំងប្រទេស សកម្មភាពមីនត្រូវបានដាក់បញ្ចូលជាសំខាន់នៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផ.យ.អ.ជ.) របស់រាជរដ្ឋាភិបាល នីតិកាលទី៧នៃរដ្ឋសភា។ សកម្មភាពមីន ត្រូវបានឃើញថាចូលរួមដល់ ការសម្រេចបានគោលដៅមួយចំនួនធំនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា ជាពិសេសគោលដៅ ទី១៨ «បញ្ចប់ផលប៉ះពាល់ជាអវិជ្ជមានរបស់មីននិងសំណល់ជាតិផ្ទុះពីសង្គ្រាម និងលើកកម្ពស់កិច្ចសង្គ្រោះ ជនរងគ្រោះ»។ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជាទី១៨ ត្រូវបានបង្កើតឡើងដើម្បីឆ្លើយតបនឹង បញ្ហាប្រឈមដែលបង្កដោយមីននិងស.ផ.ស. ដែលបន្សល់ទុកដោយសង្គ្រាមពីអតីតកាល។ ការបង្កើត គោលដៅទី១៨ បានបញ្ជាក់ពីការប្តេជ្ញាចិត្តក្នុងការដោះស្រាយបញ្ហាមីននិងស.ផ.ស. និងធានាថាសកម្មភាពមីន បានចូលរួមចំណែកដល់ការរក្សាសន្តិភាព សុខសុវត្ថិភាព និងការអភិវឌ្ឍយូរអង្វែងសម្រាប់ប្រទេសជាតិ។

ក្នុងកម្រិតអន្តរជាតិ នៅថ្ងៃទី១ ខែមករា ឆ្នាំ២០០០ ប្រទេសកម្ពុជាបានចូលជារដ្ឋភាគីនៃអនុសញ្ញា ស្តីពីការហាមការប្រើប្រាស់ ការរក្សាទុក ការផលិត និងការផ្ទេរគ្រាប់មីនប្រឆាំងមនុស្ស និងការបំផ្លាញគ្រាប់មីន (អ.ហ.ផ.ម.) ឬហៅថាអនុសញ្ញាអូតាវ៉ា ដែលបញ្ជាក់ពីការប្តេជ្ញាចិត្តរបស់ប្រទេសកម្ពុជា ក្នុងការលុបបំបាត់ គ្រាប់មីន។ ជាមួយគ្នានេះ ប្រទេសកម្ពុជាក៏បានចូលជាសមាជិកអនុសញ្ញាស្តីពីសព្វាវុធធម្មតា(CCW) និងពិធីសារ ទីI, II, III, IV និងវិសោធនកម្មពិធីសារទីII នៃអនុសញ្ញានេះ។

កាលពីថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២៣ ក្នុងកិច្ចប្រជុំលើកទី២១នៃរដ្ឋភាគីអ.ហ.ផ.ម. នៅទីក្រុងហ្សឺណែវ ប្រទេសស្វីស ប្រទេសកម្ពុជាត្រូវបានបោះឆ្នោតជ្រើសតាំងធ្វើជាប្រធាននិងម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំត្រួតពិនិត្យ ឡើងវិញលើកទី៥នៃអនុសញ្ញាអូតាវ៉ា ឆ្នាំ២០២៤។ ប្រទេសកម្ពុជា គឺជាប្រទេសដំបូងនៅអាស៊ី ដែលត្រូវបាន ជ្រើសតាំងជាប្រធាននិងម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំដ៏សំខាន់នេះ ហើយប្រទេសកម្ពុជាបានប្រសិទ្ធនាមកិច្ចប្រជុំនេះ ជា «កិច្ចប្រជុំកំពូលសៀមរាប អង្គរ ស្តីពីពិភពលោកមួយដែលគ្មានមីន» ដែលបានប្រព្រឹត្តទៅពីថ្ងៃទី២៥-២៩ ខែវិច្ឆិកា ឆ្នាំ២០២៤ នៅខេត្តសៀមរាប។ កិច្ចប្រជុំកំពូលនេះបានចូលរួមលើកកម្ពស់កិត្តិនាមនិងកិត្យានុភាព របស់ប្រទេសកម្ពុជានៅក្នុងសកម្មភាពមីនសកល ក៏ដូចជាការប្តេជ្ញាចិត្តរបស់ប្រទេសកម្ពុជាក្នុងការចូលរួម សម្រេចឱ្យបាននូវពិភពលោកមួយដែលគ្មានមីន។

ប្រទេសកម្ពុជាបានបង្កើនការប្តេជ្ញាចិត្តនៅក្នុងការជំរុញនិសព្វាវុធកម្មក្នុងតំបន់និងក្នុងពិភពលោក តាមរយៈការចូលរួមយ៉ាងសកម្មនៅក្នុងប្រតិបត្តិការរក្សាសន្តិភាព រួមទាំងការបោសសម្អាតមីន ក្រោមឆ័ត្រអង្គការ សហប្រជាជាតិ។ ជាមួយគ្នានេះ តាមរយៈមជ្ឈមណ្ឌលតំបន់អាស៊ានសម្រាប់សកម្មភាពមីន ប្រទេសកម្ពុជាបាន បង្កើនកិច្ចសហប្រតិបត្តិការតំបន់ និងបានធ្វើឱ្យប្រសើរឡើងនូវប្រសិទ្ធភាពសកម្មភាពមីននៅក្នុងតំបន់អាស៊ាន។

លើសពីនេះ ប្រទេសកម្ពុជាក៏បានដើរតួយ៉ាងសំខាន់ក្នុងការកសាងសមត្ថភាព តាមរយៈការចែករំលែកចំណេះដឹង និងជំនាញ ក្រោមក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការត្បូង ត្បូង ដើម្បីចូលរួមដោះស្រាយបញ្ហាគំរាមកំហែងដោយសារមីននិងស.ផ.ស. នៅទូទាំងពិភពលោក។

ជាងបីទសវត្សកន្លងមកនេះ កម្មវិធីបោសសម្អាតមីនមនុស្សធម៌នៅប្រទេសកម្ពុជា បានវិវត្តជាដំណាក់កាល ពីដំណាក់កាលជម្លោះ មកការរក្សាសន្តិភាពនិងស្ថិរភាព និងពីការកសាងឡើងវិញជាអាទិភាព មកការគាំទ្រការអភិវឌ្ឍ។ បច្ចុប្បន្ន សកម្មភាពមីននៅប្រទេសកម្ពុជាមានលក្ខណៈបុរេសកម្ម ដោយផ្តោតលើការគំរាមកំហែងចំពោះមុខ ក៏ប៉ុន្តែនៅដំណាក់កាលចុងក្រោយ ប្រទេសកម្ពុជានឹងឈានទៅអនុវត្តវិធីសាស្ត្រប្រតិកម្ម ដើម្បីគ្រប់គ្រងសំណល់យុទ្ធភណ្ឌគ្រឿងផ្ទុះដែលនៅសេសសល់ ប្រកបដោយប្រសិទ្ធភាព។

សំណល់យុទ្ធភណ្ឌគ្រឿងផ្ទុះដែលនៅសេសសល់ សំដៅលើសំណល់យុទ្ធភណ្ឌគ្រឿងផ្ទុះដែលបង្កហានិភ័យ បន្ទាប់ពីកិច្ចខិតខំប្រឹងប្រែងគ្រប់មធ្យោបាយសមស្រប ដើម្បីកំណត់អត្តសញ្ញាណ កត់ត្រា និងរំដោះផ្ទៃដីតាមរយៈការស្រាវជ្រាវមិនបច្ចេកទេស ការស្រាវជ្រាវបច្ចេកទេស និងការបោសសម្អាត។ កិច្ចខិតខំប្រឹងប្រែងគ្រប់មធ្យោបាយសមស្រប សំដៅលើកិច្ចខិតខំប្រឹងប្រែងដែលអាចទទួលយកបានក្នុងកម្រិតអប្បបរមា ដើម្បីកំណត់អត្តសញ្ញាណ កត់ត្រា និងបោសសម្អាតយុទ្ធភណ្ឌគ្រឿងផ្ទុះ។ កិច្ចខិតខំប្រឹងប្រែងគ្រប់មធ្យោបាយសមស្របត្រូវបានអនុវត្តពេញលេញនៅពេលដែលគេជឿជាក់ថាលទ្ធផលរំពឹងទុកមិនសមស្របនឹងធនធានដែលត្រូវចំណាយ។

ប្រទេសកម្ពុជាបានបញ្ចប់ការបោសសម្អាតមីននៅក្នុងខេត្តមួយចំនួន ស្របតាមកាតព្វកិច្ចដែលមានចែងនៅក្នុងអ.ហ.ផ.ម. ដោយជោគជ័យ ហើយនៅប៉ុន្មានឆ្នាំខាងមុខនេះ ប្រទេសកម្ពុជានឹងបន្តការបោសសម្អាតតំបន់ទាំងអស់ដែលដឹងថាមានមីននិងគ្រាប់បែកចង្កោម និងតំបន់ស.ផ.ស.ផ្សេងទៀតជាអាទិភាព។ យន្តការគ្រប់គ្រងសំណល់យុទ្ធភណ្ឌគ្រឿងផ្ទុះដែលនៅសេសសល់ អាចអនុវត្តបានជាបណ្តើរៗនៅក្នុងខេត្តដែលមានសំណល់យុទ្ធភណ្ឌគ្រឿងផ្ទុះនៅសេសសល់។ ការរៀបចំយន្តការគ្រប់គ្រងសំណល់យុទ្ធភណ្ឌគ្រឿងផ្ទុះដែលនៅសេសសល់ ចាំបាច់ឱ្យប្រទេសកម្ពុជាពិនិត្យឡើងវិញនូវក្របខ័ណ្ឌច្បាប់ ក្របខ័ណ្ឌស្ថាប័ន និងក្របខ័ណ្ឌប្រតិបត្តិការ ព្រមទាំងដាក់ចេញនូវប្រព័ន្ធ យន្តការ និងឧបករណ៍ ដែលធានាសក្តិសិទ្ធិភាពនិងចីរភាព។

អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីននិងសង្គ្រោះជនពិការដោយសារមីន( តទៅនេះ ហៅថាអាជ្ញាធរមីន )ជាស្ថាប័នដឹកនាំរៀបចំគោលនយោបាយនេះ ដោយមានការចូលរួមពីភាគីពាក់ព័ន្ធ និងបានប្រើប្រាស់ការវិភាគដោយផ្អែកលើភស្តុតាង។ គោលនយោបាយនេះរៀបចំឡើងដោយយោងលើឯកសារ សំខាន់ៗជាច្រើនរួមមានគោលនយោបាយជាតិ អន្តរជាតិផ.យ.ជ.ម. ក្របខ័ណ្ឌប្រតិបត្តិការនិងកិច្ចពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធដើម្បីប្រមូលធាតុចូល។

គោលនយោបាយជាតិស្តីពីសកម្មភាពមីន ឆ្នាំ២០២៦-២០៣៥ ផ្តើមចេញពីភាពជោគជ័យនិងបទពិសោធនៃការអនុវត្តផែនការយុទ្ធសាស្ត្រជាតិសកម្មភាពមីន ២០១៨-២០២៥ សំដៅបន្តពង្រឹងប្រសិទ្ធភាពការងារវិស័យមីន និងឆ្លុះបញ្ចាំងពីចក្ខុវិស័យវែងឆ្ងាយរបស់រាជរដ្ឋាភិបាលកម្ពុជា ឆ្លើយតបការគំរាមដែលនៅសេសសល់ និងការផ្តល់ជាផែនទីបង្ហាញផ្លូវគ្រប់ជ្រុងជ្រោយសម្រាប់សកម្មភាពមីននាពេលអនាគត។

ភាពចាំបាច់ក្នុងការរៀបចំគោលនយោបាយជាតិស្តីពីសកម្មភាពមីន ឆ្នាំ២០២៦-២០៣៥៖

- តម្រង់ទិសក្នុងការរៀបចំក្របខ័ណ្ឌច្បាប់ ក្របខ័ណ្ឌស្ថាប័ន និងក្របខ័ណ្ឌប្រតិបត្តិការ សម្រាប់វិស័យសកម្មភាពមីន ដើម្បីធានាថា ការរៀបចំរចនាសម្ព័ន្ធនិងវិធីសាស្ត្រ ឆ្លើយតបតាមតម្រូវការវិស័យនាពេលអនាគត

- អភិវឌ្ឍសមត្ថភាពជាតិ ដើម្បីគ្រប់គ្រង សម្របសម្រួល និងអនុវត្តប្រកបដោយប្រសិទ្ធភាព ក្នុងការដោះស្រាយភាពស្មុគស្មាញនៃបញ្ហាមីននិងស.ផ.ស. រួមទាំងគ្រាប់បែកចង្កោម
- ធានានូវនិរន្តរភាពបរិស្ថាន ការបញ្ជ្រាបយេនឌ័រនិងភាពចម្រុះ រួមទាំងសិទ្ធិនិងតម្រូវការរបស់ជនរងគ្រោះ និងអ្នករស់រានមានជីវិត
- ដាក់បញ្ចូលកម្មវិធីអប់រំអំពីគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ ប្រកបដោយប្រសិទ្ធភាព ដើម្បីកាត់បន្ថយផលប៉ះពាល់នៃយុទ្ធភណ្ឌគ្រឿងផ្ទុះមកលើសហគមន៍ រួមទាំងការគ្រប់គ្រង ការអប់រំអំពីគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ នៅក្នុងបរិបទនៃការគ្រប់គ្រងសំណល់គ្រឿងផ្ទុះដែលនៅសេសសល់
- លើកទឹកចិត្តដល់ការចូលរួមយ៉ាងសកម្មនិងកិច្ចសហប្រតិបត្តិការរវាងអាជ្ញាធរថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ក៏ដូចជាប្រជាជន ស្របតាមរបៀបវារៈក្របខ័ណ្ឌគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា
- ជំរុញកិច្ចសហប្រតិបត្តិការនិងជំនួយអន្តរជាតិ ស្របពេលប្រទេសកម្ពុជាបំពេញកាតព្វកិច្ចសន្ធិសញ្ញាពាក់ព័ន្ធនឹងសកម្មភាពមីន
- កៀរគរធនធានក្នុងប្រទេសនិងអន្តរជាតិដែលចាំបាច់ សម្រាប់គាំទ្រកិច្ចខិតខំប្រឹងប្រែងបោសសម្អាតមីន និងកិច្ចសង្គ្រោះជនរងគ្រោះ។

## ២- ចក្ខុវិស័យ

គោលនយោបាយជាតិស្តីពីសកម្មភាពមីន ឆ្នាំ២០២៦-២០៣៥ មានចក្ខុវិស័យ «ប្រទេសកម្ពុជារួចផុតពីផលប៉ះពាល់នៃយុទ្ធភណ្ឌគ្រឿងផ្ទុះ ធ្វើឱ្យជីវភាពរស់នៅប្រកបដោយចីរភាព ជំរុញសន្តិភាព ស្ថិរភាព និងការអភិវឌ្ឍ»។

## ៣- គោលបំណងនិងគោលដៅ

គោលនយោបាយជាតិស្តីពីសកម្មភាពមីន ឆ្នាំ២០២៦-២០៣៥ មានគោលបំណងបញ្ចប់ការបោសសម្អាតតំបន់ដែលដឹងថាមានមីននិងគ្រាប់បែកចង្កោម កាត់បន្ថយតំបន់សំណល់ជាតិផ្ទុះពីសង្គ្រាមផ្សេងទៀត និងគាំទ្រកិច្ចសង្គ្រោះជនរងគ្រោះ ប្រកបដោយចីរភាពនិងបរិយាបន្ន ដើម្បីរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងលើកកម្ពស់កិត្យានុភាពកម្ពុជាលើឆាកអន្តរជាតិ។

ដើម្បីសម្រេចបាននូវចក្ខុវិស័យនិងគោលបំណងខាងលើ គ.ជ.ស.ម.បានដាក់ចេញនូវគោលដៅចម្បងចំនួន៦ រួមមាន៖

១- រំដោះផ្ទៃដីដែលដឹងថាមានមីនទាំងអស់ត្រឹមឆ្នាំ២០៣០ និងផ្ទៃដីដែលដឹងថាមានគ្រាប់បែកចង្កោមទាំងអស់ និងផ្ទៃដីអាទិភាពដែលមានសំណល់ជាតិផ្ទុះពីសង្គ្រាមត្រឹមឆ្នាំ២០៣៥។

២- កសាងសមត្ថភាពនិងបង្កើតក្របខ័ណ្ឌជាតិប្រកបដោយចីរភាព ដើម្បីគ្រប់គ្រងសំណល់យុទ្ធភណ្ឌគ្រឿងផ្ទុះដែលនៅសេសសល់។

៣- ផ្តល់ការអប់រំអំពីគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះប្រកបដោយប្រសិទ្ធភាព ឆ្លើយតបទៅនឹងការផ្លាស់ប្តូរនៃតម្រូវការនិងបរិបទ។

៤- ផ្តល់សេវាកម្មនិងជំនួយឱ្យបានទូលំទូលាយប្រកបដោយប្រសិទ្ធភាព ជូនដល់ជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ។

៥- លើកកម្ពស់កិច្ចសហប្រតិបត្តិការនិងជំនួយអន្តរជាតិក្នុងសកម្មភាពមីនប្រកបដោយប្រសិទ្ធភាព។

៦- ធានាថាសកម្មភាពមីនឆ្លើយតបបញ្ហាអន្តរវិស័យ និងប្រើប្រាស់កត្តាជំរុញឱ្យប្រសើរឡើង។

## ៤- យុទ្ធសាស្ត្រ

ដើម្បីសម្រេចនូវចក្ខុវិស័យ គោលបំណង និងគោលដៅនៃគោលនយោបាយជាតិស្តីពីសកម្មភាពមីន ឆ្នាំ២០២៦-២០៣៥ ត្រូវផ្តោតលើយុទ្ធសាស្ត្រដូចខាងក្រោម៖

**គោលដៅទី១ : រំដោះផ្ទៃដីដែលដឹងថាមានមីនទាំងអស់ត្រឹមឆ្នាំ២០៣០ និងផ្ទៃដីដែលដឹងថាមានគ្រាប់បែកចង្កោមទាំងអស់និងផ្ទៃដីអាទិភាពដែលមានសំណល់ជាតិផ្ទុះពីសង្គ្រាមត្រឹមឆ្នាំ២០៣៥**

### ១.១- រំដោះផ្ទៃដីដែលដឹងថាមានមីនទាំងអស់ ត្រឹមឆ្នាំ២០៣០

យុទ្ធសាស្ត្រនេះផ្តោតទៅលើការរំដោះផ្ទៃដីដែលដឹងថាមានមីនទាំងអស់ នៅព្រះរាជាណាចក្រកម្ពុជា ត្រឹមឆ្នាំ២០៣០ ដោយអនុវត្តតាមសកម្មភាពជាអាទិ៍ ដូចខាងក្រោម៖

- ជំរុញការស្រាវជ្រាវមិនបច្ចេកទេស ដើម្បីរំដោះផ្ទៃដីនិងធ្វើការស្រាវជ្រាវ ដើម្បីឆ្លើយតបទៅនឹងការគំរាមកំហែងដែលកំពុងកើតមាន
- រៀបចំនិងអនុវត្តផែនការថ្នាក់ជាតិប្រចាំឆ្នាំ ដើម្បីរំដោះផ្ទៃដីដែលដឹងថាមានមីនទាំងអស់
- ជំរុញកិច្ចខិតខំប្រឹងប្រែងក្នុងការបោសសម្អាតមីនតាមតំបន់ព្រំដែន តាមយន្តការសមស្រប។

### ១.២- រំដោះផ្ទៃដីដែលដឹងថាមានគ្រាប់បែកចង្កោមទាំងអស់ត្រឹមឆ្នាំ២០៣៥

យុទ្ធសាស្ត្រនេះផ្តោតទៅលើការរំដោះផ្ទៃដីដែលដឹងថាមានគ្រាប់បែកចង្កោមទាំងអស់ត្រឹមឆ្នាំ២០៣៥ ដោយអនុវត្តតាមសកម្មភាពជាអាទិ៍ ដូចខាងក្រោម៖

- ជំរុញការស្រាវជ្រាវសំណល់គ្រាប់បែកចង្កោម ដើម្បីកំណត់ចម្ការគ្រាប់បែកចង្កោមពិត និងធ្វើការស្រាវជ្រាវ ឆ្លើយតបការគំរាមកំហែងដែលកំពុងកើតឡើង
- រៀបចំនិងអនុវត្តផែនការថ្នាក់ជាតិប្រចាំឆ្នាំ ដើម្បីរំដោះផ្ទៃដីដែលដឹងថាមានគ្រាប់បែកចង្កោមទាំងអស់។

### ១.៣- រំដោះផ្ទៃដីអាទិភាពដែលមានស.ផ.ស. ត្រឹមឆ្នាំ២០៣៥

យុទ្ធសាស្ត្រនេះផ្តោតទៅលើការរំដោះផ្ទៃដីអាទិភាពដែលមានស.ផ.ស. ត្រឹមឆ្នាំ២០៣៥ ដោយអនុវត្តតាមសកម្មភាពជាអាទិ៍ ដូចខាងក្រោម៖

- រៀបចំនិងអនុវត្តផែនការថ្នាក់ជាតិប្រចាំឆ្នាំ ដើម្បីរំដោះផ្ទៃដីអាទិភាពដែលមានស.ផ.ស.
- ផ្តល់ការឆ្លើយតបសំណើសុំកម្ទេចគ្រឿងផ្ទុះ តាមការស្នើពីសហគមន៍និងអាជ្ញាធរមូលដ្ឋានឱ្យបានទាន់ពេលវេលា។

**គោលដៅទី២ : កសាងសមត្ថភាពនិងបង្កើតក្របខ័ណ្ឌជាតិប្រកបដោយចីរភាព ដើម្បីគ្រប់គ្រងសំណល់យុទ្ធភណ្ឌគ្រឿងផ្ទុះដែលនៅសេសសល់**

### ២.១- កំណត់ស្ថាប័នពាក់ព័ន្ធ ដើម្បីគ្រប់គ្រងសំណល់យុទ្ធភណ្ឌគ្រឿងផ្ទុះដែលនៅសេសសល់ត្រឹមឆ្នាំ២០៣០

យុទ្ធសាស្ត្រនេះផ្តោតទៅលើការពិនិត្យនិងកំណត់ស្ថាប័នពាក់ព័ន្ធ ដើម្បីប្រគល់តួនាទីនិងភារកិច្ចពេញលេញក្នុងការបំពេញភារកិច្ចគ្រប់គ្រងសំណល់យុទ្ធភណ្ឌគ្រឿងផ្ទុះដែលនៅសេសសល់ ដោយអនុវត្តតាមសកម្មភាពជាអាទិ៍ ដូចខាងក្រោម៖

- សិក្សាស្រាវជ្រាវអំពីឧត្តមានុវត្តន៍និងនីតិវិធីអន្តរជាតិ ដើម្បីគ្រប់គ្រងសំណល់យុទ្ធភណ្ឌគ្រឿងផ្ទុះដែលនៅសេសសល់
- កំណត់វិសាលភាពការងារ ដើម្បីគ្រប់គ្រងសំណល់យុទ្ធភណ្ឌគ្រឿងផ្ទុះដែលនៅសេសសល់
- ពិនិត្យក្របខ័ណ្ឌស្ថាប័នជាតិ និងកំណត់ស្ថាប័នពាក់ព័ន្ធ ដើម្បីគ្រប់គ្រងសំណល់យុទ្ធភណ្ឌគ្រឿងផ្ទុះដែលនៅសេសសល់។

### ២.២- ធានាថាក្របខ័ណ្ឌគតិយុត្តត្រូវបានបង្កើតរួចរាល់ត្រឹមឆ្នាំ២០៣៥ ដើម្បីគ្រប់គ្រងសំណល់យុទ្ធភណ្ឌគ្រឿងផ្ទុះដែលនៅសេសសល់

យុទ្ធសាស្ត្រនេះផ្តោតទៅលើភាពប្រាកដប្រជានៃក្របខ័ណ្ឌគតិយុត្ត ដែលអាចឱ្យស្ថាប័នពាក់ព័ន្ធបំពេញតួនាទីនិងភារកិច្ចពេញលេញ ដោយអនុវត្តតាមសកម្មភាពជាអាទិ៍ ដូចខាងក្រោម៖

- ពិនិត្យក្របខ័ណ្ឌគតិយុត្តដែលមានស្រាប់ ដែលពាក់ព័ន្ធនឹងការគ្រប់គ្រងសំណល់យុទ្ធភណ្ឌគ្រឿងផ្ទុះដែលនៅសេសសល់
- សិក្សាស្រាវជ្រាវនិងកំណត់ឯកសារគតិយុត្តស្តីពីការទទួលខុសត្រូវ
- បង្កើតក្របខ័ណ្ឌគតិយុត្ត ដើម្បីគ្រប់គ្រងសំណល់យុទ្ធភណ្ឌគ្រឿងផ្ទុះដែលនៅសេសសល់។

### ២.៣- បង្កើតក្របខ័ណ្ឌប្រតិបត្តិការត្រឹមឆ្នាំ២០៣៥ ដើម្បីគ្រប់គ្រងសំណល់យុទ្ធភណ្ឌគ្រឿងផ្ទុះដែលនៅសេសសល់

យុទ្ធសាស្ត្រនេះផ្តោតទៅលើការធ្វើឱ្យប្រសើរឡើងនូវក្របខ័ណ្ឌប្រតិបត្តិការ ជំរុញការអនុវត្តនីតិវិធីនិងការបង្កើតយន្តការទំនាក់ទំនងសាធារណៈ ដោយអនុវត្តតាមសកម្មភាពជាអាទិ៍ ដូចខាងក្រោម៖

- ពិនិត្យក្របខ័ណ្ឌប្រតិបត្តិការដែលមានស្រាប់ ដើម្បីគ្រប់គ្រងសំណល់យុទ្ធភណ្ឌគ្រឿងផ្ទុះដែលនៅសេសសល់
- ជំរុញការអនុវត្តនីតិវិធីគ្រប់គ្រងសំណល់យុទ្ធភណ្ឌគ្រឿងផ្ទុះដែលនៅសេសសល់ នៅក្នុងក្រុង ស្រុក ខណ្ឌ រាជធានី ខេត្តអស់មីន
- បង្កើតនិងធ្វើឱ្យប្រសើរឡើងនូវក្របខ័ណ្ឌប្រតិបត្តិការ ដើម្បីគ្រប់គ្រងសំណល់យុទ្ធភណ្ឌគ្រឿងផ្ទុះដែលនៅសេសសល់
- បង្កើតនិងអនុវត្តយន្តការទំនាក់ទំនង ដើម្បីជូនដំណឹងជាសាធារណៈ។

### ២.៤- អភិវឌ្ឍសមត្ថភាពជាតិឱ្យរួចរាល់និងប្រកបដោយចីរភាពត្រឹមឆ្នាំ២០៣៥ ដើម្បីគ្រប់គ្រងសំណល់យុទ្ធភណ្ឌគ្រឿងផ្ទុះដែលនៅសេសសល់

យុទ្ធសាស្ត្រនេះផ្តោតទៅលើការអភិវឌ្ឍសមត្ថភាពស្ថាប័ន ដោយអនុវត្តតាមសកម្មភាពជាអាទិ៍ ដូចខាងក្រោម៖

- សិក្សាវាយតម្លៃតម្រូវការអភិវឌ្ឍន៍សមត្ថភាពស្ថាប័នដែលពាក់ព័ន្ធការគ្រប់គ្រងសំណល់យុទ្ធភណ្ឌគ្រឿងផ្ទុះដែលនៅសេសសល់
- អនុវត្តផែនការអភិវឌ្ឍន៍សមត្ថភាពការគ្រប់គ្រងសំណល់យុទ្ធភណ្ឌគ្រឿងផ្ទុះដែលនៅសេសសល់។

**គោលដៅទី៣ : ផ្តល់ការអប់រំអំពីគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះប្រកបដោយប្រសិទ្ធភាព ឆ្លើយតបទៅនឹងការផ្លាស់ប្តូរនៃតម្រូវការនិងបរិបទ**

**៣.១- ពិនិត្យនិងរៀបចំសារនិងសម្ភារៈអប់រំអំពីគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ ដើម្បីលើកកម្ពស់ការយល់ដឹងនិងឥរិយាបថសុវត្ថិភាព**

យុទ្ធសាស្ត្រនេះផ្តោតទៅលើការអភិវឌ្ឍសម្ភារៈអប់រំអំពីគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ ឆ្លើយតបទៅនឹងក្រុមគោលដៅ ដោយអនុវត្តតាមសកម្មភាពជាអាទិ៍ ដូចខាងក្រោម៖

- វាយតម្លៃប្រសិទ្ធភាពសារនិងសម្ភារៈអប់រំអំពីគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះដែលមានស្រាប់
- វិភាគទិន្នន័យជនរងគ្រោះនិងឥរិយាបថក្រុមប្រឈមគ្រោះថ្នាក់
- ជំរុញការចូលរួមពីសហគមន៍ក្នុងការរៀបចំផែនការនិងអនុវត្តន៍សកម្មភាពអប់រំអំពីគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ ស្របតាមតម្រូវការរបស់សហគមន៍
- រៀបចំសារនិងសម្ភារៈអប់រំអំពីគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ ផ្អែកលើការវិភាគទិន្នន័យដែលបែងចែកតាមភេទ អាយុ និងពិការភាព ដើម្បីឆ្លើយតបទៅនឹងក្រុមគោលដៅ និងការលើកកម្ពស់ឥរិយាបថសុវត្ថិភាព។

**៣.២- បញ្ចូលសកម្មភាពអប់រំអំពីគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ ក្នុងកិច្ចការស្រាវជ្រាវបោសសម្អាត និងកិច្ចសង្គ្រោះជនរងគ្រោះ រួមទាំងសកម្មភាពមីនផ្សេងៗ ដើម្បីលើកកម្ពស់ការយល់ដឹង សំដៅកាត់បន្ថយហានិភ័យក្នុងសហគមន៍រងផលប៉ះពាល់**

យុទ្ធសាស្ត្រនេះផ្តោតទៅលើការអនុវត្តកម្មវិធីអប់រំអំពីគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ តាមរយៈវិធីសាស្ត្រនានា ដោយអនុវត្តតាមសកម្មភាពជាអាទិ៍ ដូចខាងក្រោម៖

- ជំរុញការអនុវត្តការងារអប់រំអំពីគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ តាមរយៈប្រតិបត្តិការរំដោះផ្ទៃដី
- សម្របសម្រួលផ្តល់សារអប់រំអំពីគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ តាមរយៈជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ ការឆ្លើយតបបន្ទាន់ និងវេទិកាសាធារណៈសម្រាប់ជនមានពិការភាព
- ធានានិរន្តរភាពនៃកម្មវិធីអប់រំអំពីគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ ដោយការពង្រឹងរចនាសម្ព័ន្ធថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។

**៣.៣- បញ្ចូលសកម្មភាពការអប់រំអំពីគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ ទៅក្នុងការងារមនុស្សធម៌ ការអភិវឌ្ឍ កិច្ចគាំពារបរិស្ថាន ការអប់រំ សាសនា ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងវិស័យផ្សេងទៀត**

យុទ្ធសាស្ត្រនេះផ្តោតទៅលើការបញ្ជ្រាបការអប់រំអំពីគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ ទៅក្នុងវិស័យនានា ដោយអនុវត្តតាមសកម្មភាពជាអាទិ៍ ដូចខាងក្រោម៖

- ពិនិត្យនិងបន្តបញ្ជ្រាបការអប់រំអំពីគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ ទៅក្នុងកម្មវិធីសិក្សា
- បន្តពង្រឹងការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ
- សម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីបញ្ចូលការអប់រំអំពីគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ ទៅក្នុងកិច្ចការមនុស្សធម៌ ការអភិវឌ្ឍ សាសនា ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងកិច្ចគាំពារបរិស្ថាន
- ផ្តល់ជម្រើសរកប្រាក់ចំណូលដល់ក្រុមប្រឈមគ្រោះថ្នាក់ដែលគ្មានជម្រើស ដើម្បីបញ្ចៀសពួកគាត់ពីការចូលក្នុងតំបន់គ្រោះថ្នាក់។

### ៣.៤- ផ្តល់ការអប់រំអំពីគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ ដល់ក្រុមងាយរងគ្រោះនៅក្នុងតំបន់ដែលមានហានិភ័យខ្ពស់

យុទ្ធសាស្ត្រនេះផ្តោតទៅលើការផ្តល់ការអប់រំអំពីគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ ទៅក្នុងសហគមន៍ ដោយអនុវត្តតាមសកម្មភាពជាអាទិ៍ ដូចខាងក្រោម៖

- លើកកម្ពស់យុទ្ធនាការអប់រំអំពីគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ នៅក្នុងតំបន់ដែលមានហានិភ័យខ្ពស់
- ពង្រឹងបណ្តាញអប់រំអំពីគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះតាមសហគមន៍
- ផ្តល់វគ្គអប់រំអំពីគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ នៅក្នុងតំបន់ដែលមានហានិភ័យខ្ពស់
- បង្កើនប្រសិទ្ធភាពការអប់រំអំពីគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ ដោយធានាថា ទស្សនៈនិងតម្រូវការរបស់ស្ត្រី កុមារី កុមារា និងបុរស និងក្រុមងាយរងគ្រោះ ត្រូវបានគិតគូរក្នុងការរៀបចំផែនការ ការអនុវត្ត ការត្រួតពិនិត្យ និងការវាយតម្លៃនៃកម្មវិធីអប់រំអំពីគ្រោះថ្នាក់នៃយុទ្ធភណ្ឌគ្រឿងផ្ទុះ
- ធានាប្រសិទ្ធភាពនៃឧបករណ៍និងវិធីសាស្ត្រនានា ក្នុងការផ្តល់សារអប់រំអំពីគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ ឆ្លើយតបទៅនឹងការផ្លាស់ប្តូរតម្រូវការនិងបរិបទ។

## គោលដៅទី៤ : ផ្តល់សេវាកម្មនិងជំនួយឱ្យបានទូលំទូលាយប្រកបដោយប្រសិទ្ធភាពជូនដល់ជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ

### ៤.១- ធ្វើឱ្យប្រព័ន្ធទិន្នន័យជាតិសកម្មភាពមីនប្រសើរឡើង ដើម្បីគ្រប់គ្រងព័ត៌មានកិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ ប្រកបដោយប្រសិទ្ធភាព

យុទ្ធសាស្ត្រនេះផ្តោតទៅលើការបង្កើតប្រព័ន្ធគ្រប់គ្រងទិន្នន័យកិច្ចសង្គ្រោះជនរងគ្រោះ ដោយអនុវត្តតាមសកម្មភាពជាអាទិ៍ ដូចខាងក្រោម៖

- សិក្សាប្រព័ន្ធកម្មវិធីដែលមានស្រាប់ ដើម្បីកំណត់និងរៀបចំទិន្នន័យកិច្ចសង្គ្រោះជនរងគ្រោះឱ្យមានស្តង់ដា
- បង្កើតប្រព័ន្ធកម្មវិធីសម្រាប់គ្រប់គ្រងទិន្នន័យកិច្ចសង្គ្រោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ ដោយទាញយកទិន្នន័យចាំបាច់ពីភាគីពាក់ព័ន្ធ។

### ៤.២- ផ្តល់ការឆ្លើយតបបន្ទាន់ ថែទាំវេជ្ជសាស្ត្របន្ត និងផ្តល់សេវាស្តារលទ្ធភាពពលកម្មប្រកបដោយប្រសិទ្ធភាព

យុទ្ធសាស្ត្រនេះផ្តោតទៅលើការធានាផ្តល់សេវាស្តារលទ្ធភាពពលកម្មដល់ជនរងគ្រោះ ដោយអនុវត្តតាមសកម្មភាពជាអាទិ៍ ដូចខាងក្រោម៖

- ពង្រឹងការសម្របសម្រួលជាមួយភាគីពាក់ព័ន្ធ ក្នុងការឆ្លើយតបបន្ទាន់និងការថែទាំវេជ្ជសាស្ត្របន្ត
- បង្កើតយន្តការបញ្ជូនបន្តនិងផែនទីសេវាកម្ម
- ធានាសេវាស្តារលទ្ធភាពពលកម្មឱ្យបានទូលំទូលាយនិងប្រកបដោយនិរន្តរភាព
- ផ្តល់ដំណោះស្រាយមធ្យោបាយដឹកជញ្ជូនប្រកបដោយនវានុវត្តន៍ដល់ជនរងគ្រោះ ទៅកាន់មជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទា។

**៤.៣- ផ្តល់ការគាំទ្រផ្លូវចិត្តនិងចិត្តសង្គមប្រកបដោយប្រសិទ្ធភាព**

យុទ្ធសាស្ត្រនេះផ្តោតទៅលើការលើកកម្ពស់សមត្ថភាពអ្នកផ្តល់សេវាគាំទ្រផ្លូវចិត្ត ដោយអនុវត្តតាមសកម្មភាពជាអាទិ៍ ដូចខាងក្រោម៖

- បង្កើននិងលើកកម្ពស់សមត្ថភាពដល់អ្នកផ្តល់សេវាគាំទ្រផ្លូវចិត្តនិងចិត្តសង្គម
- ធានាថាជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ ទទួលបានការគាំទ្រផ្លូវចិត្តនិងចិត្តសង្គម។

**៤.៤- លើកកម្ពស់គុណភាពជីវិតរបស់ជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ តាមរយៈការធ្វើបរិយាបន្នសេដ្ឋកិច្ច សង្គម**

យុទ្ធសាស្ត្រនេះផ្តោតទៅលើការផ្តល់ជំនាញ បង្កើតឱកាសការងារសម្រាប់ជនរងគ្រោះ ដោយអនុវត្តតាមសកម្មភាពជាអាទិ៍ ដូចខាងក្រោម៖

- ផ្តល់ជំនាញដែលមានទីផ្សារ បង្កើតឱកាសការងារ និងផ្តល់ជំនួយហិរញ្ញវត្ថុចាំបាច់ដល់ជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ ដើម្បីលើកកម្ពស់ឯករាជ្យភាពសេដ្ឋកិច្ច
- ផ្តល់ការថែទាំសុខភាព សេវាសង្គម និងការគាំទ្រតាមសហគមន៍មូលដ្ឋានដល់ជនរងគ្រោះ ដើម្បីជំរុញឱ្យមានការចូលរួមពេញលេញក្នុងសកម្មភាពសង្គម។

**៤.៥- ជំរុញការអនុវត្តក្របខ័ណ្ឌគតិយុត្ត យុទ្ធសាស្ត្រ និងប្រតិបត្តិការ ដើម្បីគាំទ្រដល់ជនមានពិការភាព**

យុទ្ធសាស្ត្រនេះផ្តោតទៅលើការបង្កើតក្របខ័ណ្ឌគតិយុត្ត ដើម្បីគាំទ្រដល់ជនរងគ្រោះ ដោយអនុវត្តតាមសកម្មភាពជាអាទិ៍ ដូចខាងក្រោម៖

- បង្កើតនិងធ្វើឱ្យប្រសើរឡើងនូវក្របខ័ណ្ឌច្បាប់និងយុទ្ធសាស្ត្រ ដើម្បីគាំទ្រដល់ជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ
- ជំរុញការអនុវត្តក្របខ័ណ្ឌគតិយុត្ត យុទ្ធសាស្ត្រ និងប្រតិបត្តិការ។

**គោលដៅទី៥ : លើកកម្ពស់កិច្ចសហប្រតិបត្តិការនិងជំនួយអន្តរជាតិក្នុងសកម្មភាពមីន ប្រកបដោយប្រសិទ្ធភាព**

**៥.១- ជំរុញការចូលជាសមាជិករដ្ឋភាគីនៃអ.ហ.ផ.ម.ដោយប្រទេសមិនមែនរដ្ឋភាគី រួមទាំងលើកទឹកចិត្តប្រទេសទាំងនោះឱ្យចូលរួមក្នុងការងារនៃអនុសញ្ញា**

យុទ្ធសាស្ត្រនេះផ្តោតទៅលើការចូលរួមជំរុញឱ្យអនុសញ្ញាអ.ហ.ផ.ម.មានសមាជិកបន្ថែម ដោយអនុវត្តតាមសកម្មភាពជាអាទិ៍ ដូចខាងក្រោម៖

- គាំទ្រប្រទេសមិនមែនរដ្ឋភាគី ចូលរួមក្នុងអ.ហ.ផ.ម. តាមរយៈទំនាក់ទំនងការទូត លើកកម្ពស់កិច្ចសន្ទនា ដើម្បីបង្កើនការយល់ដឹងនិងការផ្តល់ជំនួយបច្ចេកទេស
- លើកទឹកចិត្តឱ្យមានការចូលរួមពីប្រទេសមិនមែនរដ្ឋភាគីនៅក្នុងការងារនៃអនុសញ្ញា។

### ៥.២- អនុលោមតាមកាតព្វកិច្ចក្រោមអ.ហ.ផ.ម. និងពិធីសារទីI, II, III, IV និងវិសោធនកម្មពិធីសារទីII នៃអនុសញ្ញាCCW

យុទ្ធសាស្ត្រនេះផ្តោតទៅលើការតាំងចិត្តអនុវត្តកាតព្វកិច្ចក្នុងនាមជាសមាជិកអនុសញ្ញាអ.ហ.ផ.ម. និង CCW ដោយអនុវត្តតាមសកម្មភាពជាអាទិ៍ ដូចខាងក្រោម៖

- ធានាថាកាតព្វកិច្ចក្រោមអ.ហ.ផ.ម. ជាពិសេសមាត្រា៧ ស្តីពីវិធានការតម្លាភាព និងមាត្រា៥ ស្តីពីការបំផ្លាញមីនប្រឆាំងមនុស្សក្នុងតំបន់មានមីន ត្រូវបានអនុវត្តពេញលេញ
- ធានាថាកាតព្វកិច្ចក្រោមពិធីសារទីI, II, III, IV និងវិសោធនកម្មពិធីសារទីII នៃអនុសញ្ញាCCW ត្រូវបានអនុវត្តពេញលេញ។

### ៥.៣- ជំរុញការកសាងមតិឯកភាពក្នុងចំណោមភាគីពាក់ព័ន្ធ សម្រាប់ការចូលជាសមាជិកអនុសញ្ញាCCW ពិធីសារទីV និងសិក្សាពីលទ្ធភាពនៃការចូលរួមជារដ្ឋភាគីនៃអនុសញ្ញាស្តីពីគ្រាប់បែកចង្កោម

យុទ្ធសាស្ត្រនេះផ្តោតទៅលើការចូលរួមកសាងមតិឯកភាពជាតិ ដើម្បីសិក្សាលទ្ធភាពក្នុងការចូលរួមក្នុងពិធីសារនិងអនុសញ្ញាផ្សេងទៀត ដោយអនុវត្តតាមសកម្មភាពជាអាទិ៍ ដូចខាងក្រោម៖

- ចូលរួមចំណែកក្នុងការកសាងមតិឯកភាពគ្នាក្នុងចំណោមភាគីពាក់ព័ន្ធថ្នាក់ជាតិ ឆ្ពោះទៅរកការយល់ព្រមតាមពិធីសារទីV នៃអនុសញ្ញាCCW
- ធ្វើការសិក្សាអំពីលទ្ធភាពរបស់កម្ពុជាក្នុងការចូលជាសមាជិករដ្ឋភាគីនៃអនុសញ្ញាស្តីពីគ្រាប់បែកចង្កោម។

### ៥.៤- គាំទ្រដល់ប្រតិបត្តិការរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិក្នុងសកម្មភាពមីន

យុទ្ធសាស្ត្រនេះផ្តោតទៅលើការបញ្ជូនក្រុមបោសសម្អាតមីន ចូលរួមក្នុងប្រតិបត្តិការរក្សាសន្តិភាព ដោយអនុវត្តតាមសកម្មភាពជាអាទិ៍ ដូចខាងក្រោម៖

- ធានាថាប្រតិបត្តិការសកម្មភាពមីន ក្រោមប្រតិបត្តិការរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ ត្រូវបានទទួលស្គាល់ដោយស្តង់ដាសកម្មភាពមីនអន្តរជាតិ
- បញ្ជូនក្រុមបោសសម្អាតមីននិងក្រុមកម្ទេចគ្រឿងផ្ទុះ ដែលមានគុណវុឌ្ឍិពីកងយោធពលខេមរភូមិន្ទ ចូលរួមប្រតិបត្តិការរក្សាសន្តិភាពក្រោមក្របខ័ណ្ឌអង្គការសហប្រជាជាតិ។

### ៥.៥- ពង្រឹងកិច្ចសហប្រតិបត្តិការនិងជំនួយអន្តរជាតិ តាមរយៈការចែករំលែកចំណេះដឹងនិងបទពិសោធក្នុងសកម្មភាពមីន

យុទ្ធសាស្ត្រនេះផ្តោតទៅលើការបង្កើតប្រព័ន្ធផ្លូវការ ដើម្បីចែករំលែកចំណេះដឹងនិងបទពិសោធក្នុងសកម្មភាពមីន ដោយអនុវត្តតាមសកម្មភាពជាអាទិ៍ ដូចខាងក្រោម៖

- បង្កើតប្រព័ន្ធផ្លូវការ ដោយមានការចូលរួមពីស្ថាប័នពាក់ព័ន្ធសកម្មភាពមីននៅកម្ពុជា ដើម្បីចែករំលែកចំណេះដឹង និងបទពិសោធទៅកាន់អន្តរជាតិ
- ចែករំលែកចំណេះដឹងនិងបទពិសោធក្នុងសកម្មភាពមីន ជាមួយបណ្តាប្រទេសផ្សេងៗដែលរងផលប៉ះពាល់ដោយយុទ្ធភណ្ឌគ្រឿងផ្ទុះ តាមរយៈកម្មវិធីបណ្តុះបណ្តាល ការផ្លាស់ប្តូរទស្សនកិច្ច សិក្ខាសាលា និងកិច្ចសហការផ្សេងទៀត
- បន្តលើកកម្ពស់ការស្រាវជ្រាវនិងកម្មវិធីសកម្មភាពមីនរបស់មជ្ឈមណ្ឌលតំបន់អាស៊ានសម្រាប់សកម្មភាពមីន
- បង្កើតសារមន្ទីរសកម្មភាពមីននៅរាជធានីភ្នំពេញនិងតាមបណ្តាខេត្ត ដើម្បីបង្ហាញនូវប្រវត្តិសាស្ត្រការគ្រប់គ្រង និងដំណើរការសកម្មភាពមីន។

**គោលដៅទី៦ : ធានាថា សកម្មភាពមីន ឆ្លើយតបបញ្ហាអន្តរវិស័យ និងប្រើប្រាស់កត្តាជំរុញឱ្យប្រសើរឡើង**

**៦.១- ធានាថាយេនឌ័រនិងភាពចម្រុះត្រូវបានគិតគូរក្នុងគ្រប់ទិដ្ឋភាពនៃសកម្មភាពមីន**

យុទ្ធសាស្ត្រនេះផ្តោតទៅលើការបញ្ជ្រាបយេនឌ័រនិងភាពចម្រុះក្នុងវិស័យសកម្មភាពមីន ដោយអនុវត្តតាមសកម្មភាពជាអាទិ៍ ដូចខាងក្រោម៖

- ពិនិត្យឡើងវិញនូវស្តង់ដាជាតិស្តីពីការបញ្ជ្រាបយេនឌ័រនិងភាពចម្រុះក្នុងវិស័យសកម្មភាពមីន
- ត្រួតពិនិត្យអនុលោមភាពតាមស្តង់ដាជាតិ និងការអនុវត្តការបញ្ជ្រាបយេនឌ័រនិងភាពចម្រុះក្នុងវិស័យសកម្មភាពមីន
- ធានាថាមានការបែងចែកធនធានគ្រប់គ្រាន់សម្រាប់ការបញ្ជ្រាបយេនឌ័រនិងភាពចម្រុះក្នុងវិស័យសកម្មភាពមីន។

**៦.២- ធានាថាបញ្ហាបរិស្ថាននិងការប្រែប្រួលអាកាសធាតុត្រូវបានគិតគូរក្នុងគ្រប់ទិដ្ឋភាពនៃសកម្មភាពមីន**

យុទ្ធសាស្ត្រនេះផ្តោតទៅលើការលើកកម្ពស់បញ្ហាបរិស្ថាននិងការប្រែប្រួលអាកាសធាតុក្នុងវិស័យសកម្មភាពមីន ដោយអនុវត្តតាមសកម្មភាពជាអាទិ៍ ដូចខាងក្រោម៖

- លើកកម្ពស់ការយល់ដឹងអំពីផលប៉ះពាល់បរិស្ថាននិងការប្រែប្រួលអាកាសធាតុ លើគ្រប់ទិដ្ឋភាពនៃសកម្មភាពមីន
- តាមដាន ត្រួតពិនិត្យសកម្មភាពមីន និងពង្រឹងអនុលោមភាពតាមស្តង់ដាជាតិស្តីពីការគ្រប់គ្រងបរិស្ថានក្នុងវិស័យសកម្មភាពមីន។

**៦.៣- ធានាថា កិច្ចការអភិវឌ្ឍត្រូវបានគិតគូរក្នុងគ្រប់ទិដ្ឋភាពនៃសកម្មភាពមីន**

យុទ្ធសាស្ត្រនេះផ្តោតទៅលើការគិតគូរកិច្ចការអភិវឌ្ឍក្នុងគ្រប់ទិដ្ឋភាពនៃវិស័យសកម្មភាពមីន ដោយអនុវត្តតាមសកម្មភាពជាអាទិ៍ ដូចខាងក្រោម៖

- ជំរុញការដាក់បញ្ចូលសកម្មភាពអភិវឌ្ឍន៍នៅតំបន់ដែលរងផលប៉ះពាល់ដោយសារមីននិងស.ផ.ស. ទៅក្នុងកម្មវិធីវិនិយោគឃុំ សង្កាត់
- ធ្វើការវាយតម្លៃលើផលប៉ះពាល់សេដ្ឋកិច្ច សង្គមនៃការបោសសម្អាតមីននិងស.ផ.ស.
- លើកកម្ពស់ជីវភាពរស់នៅរបស់សហគមន៍ដែលរងផលប៉ះពាល់ដោយសារមីននិងស.ផ.ស. ដើម្បីរួមចំណែកដល់ការអភិវឌ្ឍប្រកបដោយចីរភាព
- ពិនិត្យឡើងវិញលើគោលការណ៍ណែនាំស្តីពីការរៀបចំផែនការនិងចាត់អាទិភាព ឆ្លើយតបនឹងតម្រូវការសហគមន៍និងបរិការណ៍កំពុងវិវត្ត។

**៦.៤- ពង្រឹងនិរន្តរភាពហិរញ្ញវត្ថុសម្រាប់សកម្មភាពមីន**

យុទ្ធសាស្ត្រនេះផ្តោតទៅលើយុទ្ធសាស្ត្រកៀរគរធនធានវិស័យសកម្មភាពមីន ដោយអនុវត្តតាមសកម្មភាពជាអាទិ៍ ដូចខាងក្រោម៖

- ពិនិត្យឡើងវិញនូវយុទ្ធសាស្ត្រកៀរគរធនធាន
- បង្កើនភាពជាដៃគូជាមួយភាគីពាក់ព័ន្ធសំខាន់ៗ រួមមានក្រសួង ស្ថាប័នរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍ វិស័យឯកជន មូលនិធិសប្បុរសធម៌ និងសប្បុរសជន រួមទាំងប្រតិបត្តិករសកម្មភាពមីន ដើម្បីកៀរគរធនធាន
- ធានាថាការប្រើប្រាស់ធនធានសម្រាប់សកម្មភាពមីន ប្រកបដោយតម្លាភាពនិងគណនេយ្យភាព។

**៦.៥- ពង្រឹងសមត្ថភាពគ្រប់គ្រងកម្មវិធីសកម្មភាពមីនប្រកបដោយប្រសិទ្ធភាព**

យុទ្ធសាស្ត្រនេះផ្តោតទៅលើការអភិវឌ្ឍសមត្ថភាពវិស័យសកម្មភាពមីន ដោយអនុវត្តតាមសកម្មភាពជាអាទិ៍ ដូចខាងក្រោម៖

- សិក្សាវាយតម្លៃអំពីតម្រូវការសមត្ថភាពវិស័យសកម្មភាពមីន ដើម្បីកំណត់គម្លាតនិងតម្រូវការអភិវឌ្ឍន៍សមត្ថភាពនាពេលអនាគត
- បង្កើតយុទ្ធសាស្ត្រអភិវឌ្ឍន៍សមត្ថភាពឆ្លើយតបទៅនឹងតម្រូវការបុគ្គលិកនិងស្ថាប័ន ដោយផ្អែកលើលទ្ធផលនៃការសិក្សាវាយតម្លៃ
- ធានាការអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍សមត្ថភាពប្រកបដោយប្រសិទ្ធភាព។

**៦.៦- ជំរុញការប្រើប្រាស់បច្ចេកវិទ្យានិងវិធីសាស្ត្រប្រកបដោយនវានុវត្តន៍ ក្នុងវិស័យសកម្មភាពមីន**

យុទ្ធសាស្ត្រនេះផ្តោតទៅលើការអភិវឌ្ឍបច្ចេកវិទ្យាសម្រាប់សកម្មភាពមីន ដោយអនុវត្តតាមសកម្មភាពជាអាទិ៍ ដូចខាងក្រោម៖

- លើកកម្ពស់ការស្រាវជ្រាវនិងការអភិវឌ្ឍបច្ចេកវិទ្យានិងវិធីសាស្ត្រប្រកបដោយនវានុវត្តន៍ សម្រាប់សកម្មភាពមីន
- ជំរុញការប្រើប្រាស់បច្ចេកវិទ្យានិងវិធីសាស្ត្រប្រកបដោយនវានុវត្តន៍ ដើម្បីបង្កើនប្រសិទ្ធភាពសកម្មភាពមីន។

**៦.៧- បង្កើនប្រសិទ្ធភាពប្រព័ន្ធគ្រប់គ្រងព័ត៌មាន ដើម្បីលើកកម្ពស់គុណភាពទិន្នន័យ ភាពងាយស្រួលក្នុងការទាញយកនិងប្រើប្រាស់**

យុទ្ធសាស្ត្រនេះផ្តោតទៅលើការបង្កើនប្រសិទ្ធភាពប្រព័ន្ធគ្រប់គ្រងទិន្នន័យសម្រាប់សកម្មភាពមីន ដោយអនុវត្តតាមសកម្មភាពជាអាទិ៍ ដូចខាងក្រោម៖

- បង្កើនគុណភាពនៃការប្រមូលទិន្នន័យ
- ពង្រឹងសមត្ថភាព ជំរុញនវានុវត្តន៍ និងការប្រើប្រាស់បច្ចេកវិទ្យាថ្មីៗ ដើម្បីបង្កើនប្រសិទ្ធភាពនៃការវិភាគទិន្នន័យនិងប្រព័ន្ធរាយការណ៍ សម្រាប់គាំទ្រការធ្វើសេចក្តីសម្រេចចិត្ត
- ធានាថាទិន្នន័យងាយស្រួលទាញយកនិងប្រើប្រាស់។

**៦.៨- ពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងគុណភាព**

យុទ្ធសាស្ត្រនេះផ្តោតទៅលើការគ្រប់គ្រងគុណភាពសម្រាប់សកម្មភាពមីន ដោយអនុវត្តតាមសកម្មភាពជាអាទិ៍ ដូចខាងក្រោម៖

- ពិនិត្យឡើងវិញនូវស្តង់ដាជាតិនិងបទដ្ឋានប្រតិបត្តិការ ដើម្បីធានាការឆ្លើយតបទៅនឹងតម្រូវការប្រតិបត្តិការ ការរីកចម្រើនបច្ចេកវិទ្យា និងស្តង់ដាអន្តរជាតិសកម្មភាពមីន
- ធានាប្រសិទ្ធភាពនៃការអនុវត្តការគ្រប់គ្រងគុណភាព។

**៦.៩- រៀបចំនិងអនុវត្តផែនការអន្តរកាល គាំទ្រការកែសម្រួលកម្លាំងប្រតិបត្តិការសកម្មភាពមីនត្រឹមឆ្នាំ២០៣៥**

យុទ្ធសាស្ត្រនេះផ្តោតទៅលើការរៀបចំនិងអនុវត្តផែនការគាំទ្រការកែសម្រួលកម្លាំងប្រតិបត្តិការសម្រាប់សកម្មភាពមីន ដោយអនុវត្តតាមសកម្មភាពជាអាទិ៍ ដូចខាងក្រោម៖

- ពិនិត្យលើជំនាញ ឱកាសការងារ និងរៀបចំផែនការអន្តរកាល សម្រាប់គាំទ្រការកែសម្រួលកម្លាំងប្រតិបត្តិការ ការហ្វឹកហ្វឺន និងការផ្តល់ការងារឡើងវិញ
- អនុវត្តផែនការអន្តរកាលគាំទ្រការកែសម្រួលកម្លាំងប្រតិបត្តិការ។

## ៥- ផែនការសកម្មភាព

ដើម្បីសម្រេចបាននូវចក្ខុវិស័យ គោលបំណង គោលដៅ និងយុទ្ធសាស្ត្រនៃគោលនយោបាយនេះ ផែនការសកម្មភាពត្រូវអនុវត្ត រួមមាន៖

### ៥.១- ការបង្កើតយន្តការ

គោលនយោបាយជាតិស្តីពីសកម្មភាពមីន ឆ្នាំ២០២៦-២០៣៥ ត្រូវបានបង្កើតឡើងដោយផ្អែកលើយន្តការដែលមានស្រាប់ គាំទ្រដល់សកម្មភាពមីន រួមមានប្រព័ន្ធគ្រប់គ្រងដំណើរការ នីតិវិធី និងគោលការណ៍ណែនាំ ដើម្បីធានាប្រសិទ្ធភាពក្នុងការអនុវត្តការងារនិងសម្រេចលទ្ធផលចុងក្រោយដែលបានគ្រោងទុក។ ដោយសកម្មភាពមីនមនុស្សធម៌បន្តវិវត្តជាប្រចាំ យន្តការថ្មីៗមួយចំនួននឹងត្រូវបង្កើត ដាក់ឱ្យសាកល្បង ធ្វើឱ្យមានស្តង់ដា និងអនុវត្តតាមរយៈកិច្ចសហការរវាងភាគីពាក់ព័ន្ធ ប្រតិបត្តិករ និងអាជ្ញាធរមីន។

ក្នុងរយៈពេលដប់ឆ្នាំខាងមុខទៀត វិស័យសកម្មភាពមីននឹងវិវត្តទៅដំណាក់កាលគ្រប់គ្រងសំណល់យុទ្ធភណ្ឌគ្រឿងផ្ទុះដែលនៅសេសសល់ យន្តការមួយចំនួននឹងត្រូវបានបង្កើតឡើងដើម្បីសម្របសម្រួល ឆ្លើយតបរាយការណ៍ វាយតម្លៃហានិភ័យ បង្កើនការយល់ដឹងជាសាធារណៈ គ្រប់គ្រងគុណភាពនិងសកម្មភាពផ្សេងទៀត។ យន្តការទាំងនោះនឹងក្លាយជាកត្តាជំរុញក្នុងការត្រៀមខ្លួន និងធ្វើអន្តរាគមន៍ប្រកបដោយនិរន្តរភាព។ យន្តការសំខាន់មួយទៀតដែលនឹងត្រូវបង្កើតឡើងគឺ គណៈកម្មការអន្តរក្រសួងដើម្បីជាជំនួយក្នុងការកែសម្រួលកម្លាំងប្រតិបត្តិការក្នុងសកម្មភាពមីននិងការផ្តល់ការងារឡើងវិញ។ យន្តការនៃការរៀបចំផែនការ ការចាត់អាទិភាព ការសម្របសម្រួល និងកិច្ចសហការក្នុងវិស័យសកម្មភាពមីននៅកម្ពុជា ត្រូវបានទទួលស្គាល់ថា មានប្រសិទ្ធភាពខ្ពស់។ យន្តការទាំងនេះនឹងត្រូវពិនិត្យនិងធ្វើបច្ចុប្បន្នកម្មដើម្បីធានាឆ្លើយតបទៅនឹងតម្រូវការនិងការវិវត្ត។

**៥.១.១-** ការរៀបចំផែនការនិងការចាត់អាទិភាព : ការងារនេះមានសារៈសំខាន់ចំពោះភាពជោគជ័យនៃសកម្មភាពមីននៅកម្ពុជា។ យន្តការនាពេលបច្ចុប្បន្ននេះ រួមបញ្ចូលនូវវិធីសាស្ត្រពីលើចុះក្រោម និងពីក្រោមឡើងលើ ដើម្បីធានាថាធនធានបោសសម្អាតមីននិងស.ផ.ស. ត្រូវបានតម្រង់ទិសឆ្លើយតបនឹងតម្រូវការអភិវឌ្ឍន៍ និងអាទិភាពរបស់សហគមន៍។ យន្តការនេះកំណត់តំបន់អាទិភាពសម្រាប់ការបោសសម្អាត ដែលជាលទ្ធផលផែនការនេះនឹងត្រូវអនុម័តដោយថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។

នៅឆ្នាំ២០២២ យន្តការភូមិអស់មីន បានដាក់ឱ្យអនុវត្តដើម្បីលើកកម្ពស់វិស័យសកម្មភាពមីន តាមរយៈការកៀរគរធនធានថវិកាបន្ថែមពីដៃគូថ្មីៗ វិស័យឯកជន និងសាធារណជនទូទៅ ដែលជួយពន្លឿនដល់ការបោសសម្អាតមីនដែលនៅសេសសល់និងរួមចំណែកគាំទ្រដល់ការអភិវឌ្ឍសហគមន៍មូលដ្ឋាន។ យន្តការនេះក៏ចូលរួមបង្កើនប្រសិទ្ធភាពក្នុងការបោសសម្អាតមីន ដោយប្រើប្រាស់នូវវិធីសាស្ត្រនិងបច្ចេកវិទ្យាឧបករណ៍បោសសម្អាតមីនថ្មីៗដែលបានទទួលស្គាល់ដោយអាជ្ញាធរមីន និងស្របទៅតាមស្តង់ដាបទដ្ឋានប្រតិបត្តិការជាតិ។

**៥.១.២-** ការសម្របសម្រួលនិងកិច្ចសហការ : ដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយជាតិស្តីពីសកម្មភាពមីន ឆ្នាំ២០២៦-២០៣៥ ប្រទេសកម្ពុជានឹងបន្តអនុវត្តយន្តការសម្របសម្រួលទាំងបីកម្រិត រួមមាន

កម្រិតនយោបាយ(ក្រុមការងារបច្ចេកទេសចម្រុះរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍលើវិស័យសកម្មភាពមីន) កម្រិតវិស័យ(គណៈកម្មាធិការសម្របសម្រួលសកម្មភាពមីន) និងកម្រិតបច្ចេកទេស(ក្រុមការងារបច្ចេកទេស)។ បទពិសោធកន្លងមកបានបង្ហាញថា យន្តការទាំងបីកម្រិតនេះនៅតែមានប្រសិទ្ធភាពក្នុងកិច្ចការសម្របសម្រួលកិច្ចសហការ ទំនាក់ទំនង និងការលើកកម្ពស់គណនេយ្យភាព ព្រមទាំងដំណើរការដោះស្រាយបញ្ហាប្រឈម និងសម្រេចគោលដៅរបស់រាជរដ្ឋាភិបាលនិងភាគីពាក់ព័ន្ធ។

ក្រុមការងារបច្ចេកទេសចម្រុះរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍលើវិស័យសកម្មភាពមីន : ក្រុមការងារនេះដឹកនាំដោយរាជរដ្ឋាភិបាល តំណាងដោយអាជ្ញាធរមីន។ ក្រុមការងារនេះគឺជាយន្តការសម្របសម្រួលនិងពិគ្រោះយោបល់ក្នុងភាពជាដៃគូរវាងរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍ អង្គការមិនមែនរដ្ឋាភិបាល និងវិស័យឯកជន ដើម្បីពិភាក្សាអំពីផលវិបាកនៃគោលនយោបាយ ក្នុងគោលបំណងស្វែងរកដំណោះស្រាយនិងធ្វើឱ្យប្រសើរឡើងការសម្របសម្រួលក្នុងកម្រិតវិស័យ លើកកម្ពស់ការតម្រឹមនិងសុខដុមនីយកម្មជំនួយ រួមទាំងធនធានក្រៅប្រទេសសម្រាប់វិស័យសកម្មភាពមីន។

គណៈកម្មាធិការសម្របសម្រួលសកម្មភាពមីន : គណៈកម្មាធិការនេះត្រូវបានដឹកនាំដោយអាជ្ញាធរមីនដោយមានការចូលរួមពីប្រតិបត្តិករនិងដៃគូពាក់ព័ន្ធក្នុងវិស័យសកម្មភាពមីន។ គណៈកម្មាធិការនេះគឺជាយន្តការពិគ្រោះយោបល់រវាងអាជ្ញាធរមីន ប្រតិបត្តិករ និងដៃគូពាក់ព័ន្ធ ដើម្បីសម្របសម្រួលនិងតម្រង់ទិសប្រតិបត្តិការ។

ក្រុមការងារបច្ចេកទេស : ក្រុមការងារនេះត្រូវដឹកនាំដោយថ្នាក់ដឹកនាំអាជ្ញាធរមីនមួយរូប ក្នុងគោលបំណងពិភាក្សានិងស្វែងរកដំណោះស្រាយលើបញ្ហាបច្ចេកទេសគ្រប់ផ្នែកក្នុងសកម្មភាពមីន។ ក្រុមការងារបច្ចេកទេសមាន៨ផ្នែក ដូចខាងក្រោម៖

- ផ្នែកស្រាវជ្រាវនិងការបោសសម្អាតមីននិងស.ផ.ស.
- ផ្នែកអប់រំអំពីគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ
- ផ្នែកបញ្ហាបយេនឌ័រ
- ផ្នែកកិច្ចសង្គ្រោះជនពិការដោយសារមីននិងស.ផ.ស.
- ផ្នែកស្រាវជ្រាវសំណល់គ្រាប់បែកចង្កោម
- ផ្នែកគ្រប់គ្រងព័ត៌មាន
- ផ្នែកអភិវឌ្ឍសមត្ថភាព
- ផ្នែកប្រព័ន្ធត្រួតពិនិត្យការអនុវត្តសកម្មភាពមីន។

### ៥.២- ការបង្កើតក្របខ័ណ្ឌគតិយុត្ត

ដើម្បីឱ្យគ.ជ.ស.ម. អនុវត្តទៅបានប្រកបដោយប្រសិទ្ធភាព អាជ្ញាធរមីនសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យសកម្មភាពមីន ស្របតាមតម្រូវការចាំបាច់។

### ៥.៣- ការគាំទ្រហិរញ្ញវត្ថុ

ដើម្បីអនុវត្តគោលនយោបាយនេះ នឹងប្រើប្រាស់ហិរញ្ញប្បទានសម្រាប់ការអនុវត្តសកម្មភាពគាំទ្រ ដែលមានប្រភពពីថវិកាជាតិ ហិរញ្ញប្បទាន សហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍ វិស័យឯកជន ព្រមទាំងប្រភពស្របច្បាប់ផ្សេងទៀត។ បន្ថែមពីនេះ ប្រភពហិរញ្ញប្បទាននិងជំនួយគាំទ្រដទៃទៀត អាចស្វែងរកពីដៃគូអភិវឌ្ឍ វិស័យឯកជន ព្រមទាំងថវិកាដែលបានមកពីប្រភពស្របច្បាប់ផ្សេងទៀត។

## ៥.៤- ការបណ្តុះបណ្តាលធនធានមនុស្ស

ដើម្បីអនុវត្តគោលនយោបាយជាតិស្តីពីសកម្មភាពមីន ឆ្នាំ២០២៦-២០៣៥ ប្រកបដោយប្រសិទ្ធភាព វិស័យសកម្មភាពមីនត្រូវលើកកម្ពស់ការអភិវឌ្ឍសមត្ថភាពបីកម្រិតសំខាន់ៗ : កម្រិតបុគ្គល កម្រិតស្ថាប័ន និងកម្រិតកត្តាជំរុញមជ្ឈដ្ឋានខាងក្រៅ។

- កម្រិតបុគ្គល : ធ្វើឱ្យប្រសើរឡើងនូវជំនាញ ចំណេះដឹង និងសមត្ថភាពរបស់បុគ្គល ដើម្បីអាចអនុវត្តតួនាទីនិងភារកិច្ចប្រកបដោយប្រសិទ្ធភាព
- កម្រិតស្ថាប័ន : ការពង្រឹងប្រព័ន្ធ ដំណើរការ រចនាសម្ព័ន្ធផ្ទៃក្នុង និងធនធានរបស់ស្ថាប័ន ដោយពង្រឹងសមត្ថភាពរបស់ស្ថាប័នក្នុងការបំពេញអាណត្តិការងារនិងការផ្តល់សេវា
- កម្រិតកត្តាជំរុញមជ្ឈដ្ឋានខាងក្រៅ : បង្កលក្ខណៈងាយស្រួលដល់បុគ្គលិកនិងស្ថាប័នក្នុងដំណើរការបំពេញការងារ ដោយការបង្កើតគោលនយោបាយ ច្បាប់ វិទ្យាស្ថាន និងនិយាមសង្គមវប្បធម៌ដែលគាំទ្រដល់ការអភិវឌ្ឍ។

## ៥.៥- ដំណើរការអនុវត្តគម្រោង

នៅក្រោមក្របខ័ណ្ឌនៃគោលនយោបាយជាតិស្តីពីសកម្មភាពមីន ឆ្នាំ២០២៦-២០៣៥ ផែនការអនុវត្តនឹងត្រូវរៀបចំឡើងដើម្បីអនុវត្តគោលដៅនីមួយៗ សំដៅសម្រេចបានជោគជ័យនូវគោលបំណងនៃគោលនយោបាយនេះ។ ផែនការអនុវត្តនឹងរៀបចំភ្លាមៗ ដោយកំណត់ពេលវេលា ស្របតាមគោលដៅនៃគោលនយោបាយនេះ។

៥.៥.១- អាទិភាពការងារ

- បង្កើនប្រសិទ្ធភាពបោសសម្អាតមីន គ្រាប់បែកចង្កោម និងសំណល់ជាតិផ្ទុះពីសង្គ្រាម ដើម្បីធានាសុវត្ថិភាពដល់សហគមន៍ដែលរងផលប៉ះពាល់ តាមរយៈការធ្វើផែនការ ការពង្រាយកម្លាំងប្រតិបត្តិការ ការបណ្តុះបណ្តាល ការច្នៃប្រឌិត និងការប្រើប្រាស់បទពិសោធល្អៗ
- ពង្រឹងប្រសិទ្ធភាពនៃការអប់រំអំពីគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ ដើម្បីកាត់បន្ថយអត្រាគ្រោះថ្នាក់ និងលើកកម្ពស់កិច្ចសង្គ្រោះជនរងគ្រោះ ក្នុងបំណងធ្វើឱ្យប្រសើរឡើងនូវគុណភាពជីវិតរបស់ជនរងគ្រោះ
- ជំរុញសកម្មភាពមីនដែលពន្លឿនកំណើនសេដ្ឋកិច្ចនិងលុបបំបាត់ភាពក្រីក្រ ដើម្បីជាប្រយោជន៍ដល់សហគមន៍មូលដ្ឋាន
- រៀបចំផែនការអនុវត្តរយៈពេល៣ឆ្នាំដំបូង ដែលស្របតាមគោលបំណងនិងគោលដៅនៃគោលនយោបាយជាតិស្តីពីសកម្មភាពមីន រួមបញ្ចូលផែនការត្រួតពិនិត្យនិងវាយតម្លៃគ្រប់ជ្រុងជ្រោយ។ លើសពីនេះ ជំរុញការរៀបចំផែនការប្រចាំឆ្នាំដោយភាគីពាក់ព័ន្ធ ដើម្បីធានានូវឱ្យនភាព និងភាពបត់បែនស្របតាមផែនការអនុវត្តនេះ
- រៀបចំយុទ្ធសាស្ត្រកៀរគរធនធានគ្រប់ជ្រុងជ្រោយ ដោយផ្តោតលើវិធីសាស្ត្រប្រកបដោយនវានុវត្តន៍ ពិពិធកម្មប្រភពថវិកា និងការបែងចែកធនធានប្រកបដោយតម្លាភាព
- ពិនិត្យនិងបង្កើតក្របខ័ណ្ឌស្ថាប័ននិងក្របខ័ណ្ឌគតិយុត្ត ដើម្បីកំណត់តួនាទីនិងភារកិច្ច គ្រប់គ្រងនិងត្រួតពិនិត្យវិស័យសកម្មភាពមីន ជាពិសេសគាំទ្រដល់ដំណាក់កាលគ្រប់គ្រងសំណល់យុទ្ធភណ្ឌគ្រឿងផ្ទុះដែលនៅសេសសល់

- បន្តអភិវឌ្ឍប្រកបដោយចីរភាព នូវសមត្ថភាពក្នុងការគ្រប់គ្រងសំណល់យុទ្ធភណ្ឌគ្រឿងផ្ទុះដែលនៅសេសសល់
- ពិនិត្យនិងកែលម្អយន្តការ ស្តង់ដាសកម្មភាពកម្ចាត់មីនកម្ពុជា បទដ្ឋានប្រតិបត្តិការ និងគោលការណ៍ណែនាំដែលមានស្រាប់ ដើម្បីធានាថាយន្តការនិងឯកសារទាំងនេះនៅតែមានភាពចាំបាច់ ឆ្លុះបញ្ចាំងពីឧត្តមានុវត្តន៍នាពេលបច្ចុប្បន្ន និងឆ្លើយតបទៅនឹងការវិវត្តនៃវិស័យ
- បង្កើត សាកល្បង និងអនុវត្តយន្តការ ស្តង់ដាសកម្មភាពកម្ចាត់មីនកម្ពុជា បទដ្ឋានប្រតិបត្តិការ គោលការណ៍ណែនាំថ្មីៗ ដើម្បីឆ្លើយតបតម្រូវការដែលកំពុងកើតមាន ជាពិសេសត្រៀមខ្លួនឈានទៅរកដំណាក់កាលគ្រប់គ្រងសំណល់យុទ្ធភណ្ឌគ្រឿងផ្ទុះដែលនៅសេសសល់។

### ៥.៥.២- ការគ្រប់គ្រងហានិភ័យ

ការអនុវត្តគោលនយោបាយជាតិស្តីពីសកម្មភាពមីន ឆ្នាំ២០២៦-២០៣៥ អាចប្រឈមនឹងបញ្ហាមួយចំនួនដូចជាដំណើរការប្រតិបត្តិការ ស្ថានភាពភូមិសាស្ត្រ ធនធានហិរញ្ញវត្ថុជាដើម ដែលត្រូវតែមានដំណោះស្រាយជាយុទ្ធសាស្ត្រដើម្បីធានានូវភាពជោគជ័យ។ ឧបសគ្គសំខាន់ៗ រួមមានស្ថានភាពភូមិសាស្ត្រចម្ការមីននៅតំបន់ព្រំដែន ការរកឃើញទីតាំងថ្មីដែលមានការគំរាម តំបន់ព្រំដែនមិនទាន់បញ្ចប់ការខណ្ឌសីមា និងធនធានហិរញ្ញវត្ថុ។

- ស្ថានភាពភូមិសាស្ត្រចម្ការមីននៅតំបន់ព្រំដែន : ចម្ការមីននៅតាមបណ្តោយព្រំដែនកម្ពុជា ថៃ ស្ថិតក្នុងតំបន់ភ្នំដែលមានជម្រាល រដិបរដុប និងស្ថិតក្នុងព្រៃស្រោង ពិបាកធ្វើដំណើរចូលទៅដល់។ ក្នុងស្ថានភាពនេះ ការវាយតម្លៃភូមិសាស្ត្រនិងការបោសសម្អាតមីននឹងត្រូវធ្វើឡើងដោយប្រើប្រាស់បច្ចេកវិទ្យាសមស្រប ហើយបុគ្គលិកបោសសម្អាតមីនត្រូវមានសមត្ថភាពគ្រប់គ្រាន់និងទទួលបានការបណ្តុះបណ្តាលជាប្រចាំ។ ជាមួយគ្នានេះ ឧបករណ៍បោសសម្អាតមីន បទដ្ឋានប្រតិបត្តិការ និងការរៀបចំផែនការ ត្រូវត្រួតពិនិត្យជាប្រចាំដើម្បីឱ្យស្របតាមស្ថានភាពភូមិសាស្ត្រនិងពេលវេលា
- ការរកឃើញទីតាំងថ្មីដែលមានការគំរាម : ឆ្លើយតបទៅនឹងការរកឃើញទីតាំងថ្មីដែលមានការគំរាម វិធីសាស្ត្រសមស្របនឹងត្រូវអនុវត្តដោយការដាក់ពង្រាយក្រុមបោសសម្អាតមីនពហុជំនាញ។ ក្រុមទាំងនេះត្រូវមានជំនាញស្រាវជ្រាវមិនបច្ចេកទេស ស្រាវជ្រាវបច្ចេកទេស និងបោសសម្អាតប្រកបដោយប្រសិទ្ធភាព។ យន្តការឆ្លើយតបរហ័សនឹងត្រូវបង្កើតឡើង ដែលអនុញ្ញាតឱ្យក្រុមទាំងនេះឆ្លើយតបបានភ្លាមៗ សម្រាប់តំបន់គ្រោះថ្នាក់ដែលបានកំណត់អត្តសញ្ញាណថ្មី។ ការរកឃើញបែបនេះនឹងត្រូវបំពេញនៅក្នុងទម្រង់ស្រាវជ្រាវ ចងក្រងជាឯកសារ និងកត់ត្រាជាតំបន់ថ្មីដែលមានការគំរាម ដែលត្រូវផ្តល់អាទិភាពសម្រាប់ប្រតិបត្តិការបោសសម្អាតជាបន្តបន្ទាប់
- តំបន់ព្រំដែនមិនទាន់បញ្ចប់ការខណ្ឌសីមា : តំបន់ព្រំដែនមិនទាន់បញ្ចប់ការខណ្ឌសីមា បង្កនូវហានិភ័យខ្ពស់ ជាឧបសគ្គក្នុងការចេញចូល អាចបង្កជាជម្លោះ និងរារាំងដល់សកម្មភាពបោសសម្អាតមីន។ ភាពមិនប្រាកដប្រជាបែបនេះអាចពន្យារពេលប្រតិបត្តិការ និងប៉ះពាល់ដល់វឌ្ឍនភាពនៃការអនុវត្តផែនការការងារ។ ប្រទេសកម្ពុជានឹងបន្តដោះស្រាយបញ្ហាទាក់ទងនឹងព្រំដែន តាមរយៈការសន្ទនាដោយសន្តិវិធី និងកិច្ចសហប្រតិបត្តិការបោសសម្អាតមីន ស្របតាមកាតព្វកិច្ចក្រោមអ.ហ.ផ.ម. និងក្នុងក្របខ័ណ្ឌនៃគណៈកម្មាធិការព្រំដែនទូទៅនិងគណៈកម្មការចម្រុះខណ្ឌសីមាព្រំដែនគោក
- ធនធានហិរញ្ញវត្ថុ : ការធ្វើវិភាជន៍ថវិកាបានគ្រប់គ្រាន់និងទាន់ពេលវេលា មានសារៈសំខាន់សម្រាប់ការអនុវត្តផែនការការងារ។ ការយឺតយ៉ាវ ការខ្វះខាត ឬការបង្វែរទិសដៅធនធានហិរញ្ញវត្ថុ អាចជា



A^ u8

ឧបសគ្គដល់ការសម្រេចបាននូវផែនការប្រតិបត្តិការ ដោយធ្វើឱ្យខ្វះខាតសម្ភារៈនិងធនធានមនុស្ស និងប៉ះពាល់ដល់គុណភាពប្រតិបត្តិការសកម្មភាពបោសសម្អាតមីន ដែលនាំឱ្យមិនអាចសម្រេចបាននូវគោលបំណងដែលមានចែងនៅក្នុងគោលនយោបាយជាតិស្ដីពីសកម្មភាពមីន ឆ្នាំ២០២៦-២០៣៥។ ដើម្បីដោះស្រាយបញ្ហានេះ ប្រទេសកម្ពុជានឹងធ្វើពិពិធកម្មប្រភពថវិកា ដោយរៀបចំឱ្យមានការចូលរួមពីម្ចាស់ជំនួយថ្មី និងវិស័យឯកជន សម្រាប់គាំទ្រផ្នែកហិរញ្ញវត្ថុរយៈពេលវែង។ ជាមួយគ្នានេះការបង្កើតទុនបម្រុងជាតិឬមូលនិធិសង្គ្រោះបន្ទាន់ ក៏ជាវិធីសាស្ត្រមួយក្នុងការបំពេញបន្ថែមក្នុងអំឡុងពេលដែលមានការខ្វះចន្លោះថវិកា។ ការធ្វើសមាហរណកម្មសកម្មភាពមីនទៅក្នុងថវិកាជាតិនិងតាមវិស័យ ជាពិសេសក្នុងវិស័យអភិវឌ្ឍន៍ជនបទ កសិកម្ម និងហេដ្ឋារចនាសម្ព័ន្ធ អាចបើកឱកាសទទួលបានហិរញ្ញប្បទានក្នុងស្រុក និងសហហិរញ្ញប្បទានថ្មីៗ។ ការពង្រឹងផែនការហិរញ្ញវត្ថុសម្រាប់រយៈពេលវែង ការកំណត់បែបបទថវិកាដែលមានលក្ខណៈបត់បែន និងការផ្ដល់អាទិភាពលើការប្រើប្រាស់វិធីសាស្ត្រដែលមានប្រសិទ្ធភាពចំណាយ ដូចជាការស្រាវជ្រាវមិនបច្ចេកទេស នឹងជំរុញការប្រើប្រាស់ធនធានឱ្យកាន់តែមានប្រសិទ្ធភាព។ ជាចុងក្រោយ ការពង្រឹងទំនាក់ទំនងជាមួយសហគមន៍ផ្ដល់ជំនួយតាមរយៈការរាយការណ៍ប្រកបដោយតម្លាភាព និងផ្អែកលើលទ្ធផលក៏នឹងជួយរក្សាទំនុកចិត្តនិងការគាំទ្រផ្នែកថវិកាផងដែរ។

## ៦- ការតាមដានត្រួតពិនិត្យនិងការវាយតម្លៃ

ការតាមដានត្រួតពិនិត្យនិងការវាយតម្លៃ មានសារៈសំខាន់ក្នុងការសម្រេចនូវគោលបំណងដែលមានចែងនៅក្នុងគោលនយោបាយជាតិស្ដីពីសកម្មភាពមីន ឆ្នាំ២០២៦-២០៣៥ ដើម្បីធានាការអនុវត្តដែលនឹងសម្រេចបាននូវលទ្ធផលដូចបានគ្រោងទុក ការប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាព និងបន្តជំរុញការកែលម្អជាប្រចាំ។ ភាគីពាក់ព័ន្ធសកម្មភាពមីននៅកម្ពុជា ប្ដេជ្ញាចិត្តក្នុងការកែលម្អប្រព័ន្ធត្រួតពិនិត្យនិងវាយតម្លៃ ដើម្បីធានាបាននូវគណនេយ្យភាព សុវត្ថិភាព និងសក្តិសិទ្ធិភាព។ ការត្រួតពិនិត្យនិងវាយតម្លៃនេះ ត្រូវបានដាក់បញ្ចូលនៅគ្រប់ដំណាក់កាលនៃវដ្តសកម្មភាពមីន(ការរៀបចំផែនការ ការអនុវត្តផែនការ និងសកម្មភាពក្រោយការអនុវត្តផែនការ) ដើម្បីតម្រង់ទិសដល់ការសម្រេចចិត្ត និងការធ្វើវិភាជន៍ធនធានប្រកបដោយប្រសិទ្ធភាព។

ការតាមដានត្រួតពិនិត្យ : វឌ្ឍនភាពនៃការអនុវត្តគោលនយោបាយនេះនឹងត្រូវបានតាមដាននិងវាស់វែងតាមរយៈតារាងសូចនាករសម្រាប់អនុវត្តសកម្មភាពនៃផែនការអនុវត្តបីឆ្នាំ ដែលនឹងត្រូវរៀបចំជារបាយការណ៍រៀងរាល់បីឆ្នាំ។ ប្រព័ន្ធនេះត្រូវបានរៀបចំឡើងឆ្លើយតបទៅនឹងការវិវត្តនៃវិស័យសកម្មភាពមីន និងតម្រូវការសហគមន៍។ អាជ្ញាធរមីននឹងបន្តប្រើប្រាស់ប្រព័ន្ធត្រួតពិនិត្យការអនុវត្តសកម្មភាពមីន ដែលមានប្រសិទ្ធភាពសម្រាប់បន្តការវាយតម្លៃនិងការកែលម្អការអនុវត្ត ការរៀបចំផែនការ និងចាត់អាទិភាពនៃការបោសសម្អាតមីន។ ក្របខ័ណ្ឌតាមដាននិងវាយតម្លៃនេះ ក៏នឹងរួមបញ្ចូលនូវការត្រួតពិនិត្យជាប្រចាំលើហានិភ័យនានាដែលបានកំណត់នៅក្នុងផ្នែកទី៧ ផងដែរ។

ការវាយតម្លៃ : ការវាយតម្លៃនឹងដើរតួនាទីសំខាន់ ក្នុងការវាស់វែងការអនុវត្តនិងលទ្ធផលនៃកម្មវិធីសកម្មភាពមីន ក្រោមគោលនយោបាយជាតិស្ដីពីសកម្មភាពមីន ឆ្នាំ២០២៦-២០៣៥។ ការវាយតម្លៃទាំងនេះនឹងវាស់វែងលើសមាសធាតុនានា រួមមានភាពចាំបាច់ ប្រសិទ្ធភាព និរន្តរភាព សុវត្ថិភាព និងលទ្ធផលរយៈពេលវែងនៃការអនុវត្តការងារដោយប្រើប្រាស់វិធីសាស្ត្រចម្រុះ។ ការវាយតម្លៃពាក់កណ្ដាលអាណត្តិនៃការអនុវត្តគោលនយោបាយនេះ នឹងធ្វើនៅឆ្នាំ២០៣០ ដើម្បីវាស់វែងនូវវឌ្ឍនភាព កំណត់បញ្ហាប្រឈម កែលម្អការអនុវត្ត

ជានាគណនេយ្យភាព ផ្តល់ជាជំនួយក្នុងការសម្រេចចិត្ត និងកត់ត្រាមេរៀននិងបទពិសោធល្អៗ។ ការវាយតម្លៃចុងក្រោយនឹងធ្វើនៅឆ្នាំ២០៣៥ ដើម្បីវាស់វែងសមិទ្ធផលសម្រេចបាននៃការអនុវត្តគោលនយោបាយ។ ការវាយតម្លៃទាំងពីរនេះ នឹងត្រូវធ្វើឡើង ដោយមានការចូលរួមសហការពីក្រសួង ស្ថាប័នរាជរដ្ឋាភិបាល សហគមន៍ផ្តល់ជំនួយ អង្គការសកម្មភាពមីន និងសហគមន៍មូលដ្ឋាន ដើម្បីជានានូវតម្លាភាព។

## ៧- សេចក្តីសន្និដ្ឋាន

ប្រទេសកម្ពុជាសម្រេចបាននូវវឌ្ឍនភាពសកម្មភាពមីនគួរឱ្យកត់សម្គាល់ក្នុងរយៈពេលជាង៣ទសវត្សកន្លងមកនេះ តាមរយៈការស្រាវជ្រាវ ការបោសសម្អាត ការអប់រំកាត់បន្ថយគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ និងកិច្ចសង្គ្រោះជនរងគ្រោះ ដែលបានជួយសង្គ្រោះអាយុជីវិតប្រជាពលរដ្ឋ លុបបំបាត់ការភ័យខ្លាច និងបានបោសសម្អាតដីដែលដឹងថាមានមីនឱ្យមានសុវត្ថិភាពជូនដល់សហគមន៍ សម្រាប់បម្រើក្នុងវិស័យកសិកម្ម លំនៅឋាន ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ និងការអភិវឌ្ឍនានា។ សកម្មភាពមីនបានចូលរួមចំណែកដោយផ្ទាល់និងប្រយោលក្នុងការកាត់បន្ថយភាពក្រីក្រ បង្កើនភាពធន់ និងស្តារឡើងវិញនូវជីវភាព និងសេចក្តីថ្លៃថ្នូររបស់សហគមន៍និងជនរងគ្រោះដោយសារមីននិងស.ផ.ស. ហើយទន្ទឹមគ្នានេះក៏លើកកម្ពស់កិត្តិនាមរបស់កម្ពុជាលើឆាកអន្តរជាតិផងដែរ។

ដោយផ្ទៃដីរងផលប៉ះពាល់ដោយសារមីននិងស.ផ.ស. នៅមានទំហំធំធេង រាជរដ្ឋាភិបាលនៅតែរក្សាសកម្មភាពមីនជាវិស័យអាទិភាព ដូចមានកំណត់នៅក្នុងយុទ្ធសាស្ត្រនិងផែនការអភិវឌ្ឍន៍ជាតិ។ ស្របតាមយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ រាជរដ្ឋាភិបាលបានរៀបចំនិងដាក់ចេញនូវគោលនយោបាយជាតិស្តីពីសកម្មភាពមីន ឆ្នាំ២០២៦-២០៣៥ ដោយបានគិតគូរច្បាស់លាស់ និងមានការពិគ្រោះយោបល់គ្រប់ជ្រុងជ្រោយ និងផ្អែកលើបទពិសោធនៃការអនុវត្តផ.យ.ជ.ម. ២០១៨-២០២៥។

ឈរលើគោលការណ៍ភាពជាម្ចាស់ការ បរិយាបន្ន និងនវានុវត្តន៍ គោលនយោបាយនេះបានដាក់ចេញនូវចក្ខុវិស័យ គោលបំណង គោលដៅ និងយុទ្ធសាស្ត្រ ដោយបានកំណត់ទិសដៅរយៈពេល១០ឆ្នាំ ដែលមានលក្ខណៈប្រទាក់ក្រឡាគ្នា ផ្តោតសំខាន់លើការធានានូវប្រសិទ្ធភាពនៃការបោសសម្អាត ការអប់រំកាត់បន្ថយគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ កិច្ចសង្គ្រោះជនរងគ្រោះ ការគ្រប់គ្រងប្រព័ន្ធទិន្នន័យ ការបញ្ជ្រាបយេនឌ័រ និងការការពារបរិស្ថាន ការពង្រឹងសមត្ថភាពជាតិ និងការបង្កើនកិច្ចសហប្រតិបត្តិការអន្តរជាតិ។ ជាមួយគ្នានេះ តាមរយៈគោលនយោបាយជាតិនេះ ប្រទេសកម្ពុជាបានគូសបញ្ជាក់ថា និរន្តរភាពនៃសកម្មភាពមីន ទាមទារការចូលរួមសកម្មពីគ្រប់ដៃគូពាក់ព័ន្ធ ទាំងក្នុងប្រទេសនិងក្រៅប្រទេស ហើយប្រទេសកម្ពុជានឹងពង្រីកវិសាលភាពនៃការចែករំលែកបទពិសោធ ជំនាញ និងចំណេះដឹងរបស់ខ្លួន ទៅកាន់ប្រទេសរងគ្រោះផ្សេងទៀតនៅទូទាំងពិភពលោក តាមរយៈកិច្ចសហប្រតិបត្តិការទ្វេភាគីនិងពហុភាគី។

គោលនយោបាយជាតិស្តីពីសកម្មភាពមីន ឆ្នាំ២០២៦-២០៣៥ គឺជាផែនទីបង្ហាញផ្លូវ និងជាការប្តេជ្ញារបស់រាជរដ្ឋាភិបាល ក្នុងការការពារសន្តិភាព ស្ថិរភាព សុខសុវត្ថិភាពរបស់ប្រជាជន និងប្រែក្លាយសកម្មភាពមីនឱ្យក្លាយជាកាតាលីករមួយ ដែលចូលរួមជំរុញដល់ការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍសេដ្ឋកិច្ច សង្គម ប្រកបដោយចីរភាពនិងបរិយាបន្ន។ តាមរយៈការអនុវត្តគោលនយោបាយនេះ ប្រទេសកម្ពុជានឹងសម្រេចបាននូវគោលដៅ រួចផុតពីផលប៉ះពាល់នៃយុទ្ធភណ្ឌគ្រឿងផ្ទុះ ដែលនឹងលែងជាឧបសគ្គដល់ការរីកចម្រើនរបស់ប្រទេសជាតិនិងសុខុមាលភាពរបស់ប្រជាជន។

# សទ្ទានុក្រម

| | |
|---|---|
| ការរំដោះផ្ទៃដី | ដំណើរការនៃការអនុវត្តគ្រប់មធ្យោបាយដែលសមស្រប ដើម្បីបញ្ជាក់ កំណត់ និង យកចេញនូវការសង្ស័យនិងវត្តមានមីននិង/ឬស.ផ.ស. តាមរយៈការស្រាវជ្រាវមិនបច្ចេកទេស ការស្រាវជ្រាវបច្ចេកទេស និងការបោសសម្អាតទាំងស្រុង។ |
| ការស្រាវជ្រាវមិនបច្ចេកទេស | ការរំដោះផ្ទៃដីដែលសង្ស័យមានការគំរាមដោយសារមីននិង/ឬស.ផ.ស. តាមរយៈការប្រមូលនិងវិភាគទិន្នន័យនិងព័ត៌មាន ដោយពុំចាំបាច់ប្រើប្រាស់ឧបករណ៍បោសសម្អាត។ |
| ការស្រាវជ្រាវបច្ចេកទេស | ការរំដោះផ្ទៃដីដែលសង្ស័យមានការគំរាមដោយសារមីននិង/ឬស.ផ.ស. តាមរយៈការប្រមូលនិងវិភាគទិន្នន័យនិងព័ត៌មាន និងប្រើប្រាស់ឧបករណ៍បោសសម្អាតសមស្រប ដើម្បីបញ្ជាក់ថាផ្ទៃដីលែងមានការគំរាម។ |
| ការបោសសម្អាតទាំងស្រុង | ការយកចេញនិង/ឬការបំផ្លាញចោលគ្រាប់មីននិង/ឬស.ផ.ស. ពីតំបន់គោលដៅតាមជម្រៅដែលបានកំណត់ក្នុងកិច្ចសន្យា កិច្ចព្រមព្រៀង ឬនៅក្នុងផែនការ។ |
| ការបោសសម្អាតមីនមនុស្សធម៌ | ការយកចេញនិងបំផ្លាញចោលគ្រាប់មីននិង/ឬស.ផ.ស. ដើម្បីការពារជីវិតនិងសុវត្ថិភាពប្រជាជន បោសសម្អាតដីដែលមានមីនឱ្យមានសុវត្ថិភាពសម្រាប់ប្រើប្រាស់ឡើងវិញ និងគាំទ្រការអភិវឌ្ឍសេដ្ឋកិច្ច សង្គម នៅតំបន់ដែលទទួលរងផលប៉ះពាល់។ |
| កិច្ចសហប្រតិបត្តិការត្បូង ត្បូង | កិច្ចសហប្រតិបត្តិការដែលប្រទេសកំពុងអភិវឌ្ឍធ្វើការរួមគ្នាដើម្បីស្វែងរកដំណោះស្រាយលើបញ្ហាប្រឈមរួមនៃការគ្រប់គ្រងសកម្មភាពមីន ដោយចែករំលែកបទពិសោធនៃការអនុវត្តដោយជោគជ័យតាមបរិបទនៃប្រទេសនីមួយៗ ដោយព្យាយាមចូលរួមផ្តល់កិច្ចសហការឈានទៅសម្រេចបានការលុបបំបាត់ហានិភ័យដែលបង្កឡើងដោយយុទ្ធភណ្ឌគ្រឿងផ្ទុះ។ |
| បុរេសកម្ម | ដំណាក់កាលដែលមានការរៀបចំគិតគូរទុកជាមុន ដើម្បីដោះស្រាយបញ្ហាមីននិង/ឬស.ផ.ស. ប្រកបដោយប្រសិទ្ធភាពនិងចំគោលដៅ។ |
| ប្រតិកម្ម | ដំណាក់កាលនៃការឆ្លើយតបទៅនឹងតម្រូវការ ដើម្បីកំណត់ទំហំនៃការស្រាវជ្រាវ ការយកចេញ ការកម្ទេច និងការបោសសម្អាតមីននិង/ឬស.ផ.ស.។ |
| យុទ្ធភណ្ឌគ្រឿងផ្ទុះ | គ្រាប់ដែលមានផ្ទុកវំសេវផ្ទុះ រួមមានមីន គ្រាប់បែកចង្កោម គ្រាប់មិនទាន់ផ្ទុះ គ្រាប់ដែលបោះបង់ចោល ខ្សែអន្ទាក់បង្កៃ គ្រាប់កែច្នៃ និងគ្រាប់ផ្សេងទៀត។ |
| វិធីសាស្ត្រពីលើចុះក្រោម | ការតម្រង់ទិសពីថ្នាក់ជាតិ ដើម្បីរៀបចំបញ្ជីភូមិ/ឃុំអាទិភាពផ្អែកលើលក្ខណៈវិនិច្ឆ័យមួយចំនួន សម្រាប់គាំទ្រថ្នាក់ក្រោមជាតិរៀបចំផែនការបោសសម្អាតមីននិង/ឬស.ផ.ស.។ |

| | |
|---|---|
| វិធីសាស្ត្រពីក្រោមឡើងលើ | ផ្អែកលើបញ្ជីភូមិ/ឃុំអាទិភាព ក្រុមការងារផែនការសកម្មភាពកំចាត់មីន ធ្វើការសម្របសម្រួលជាមួយអាជ្ញាធរមូលដ្ឋាននិងប្រតិបត្តិករ ដើម្បីជ្រើសរើសចម្ការមីន និង/ឬស.ផ.ស. ជាអាទិភាពរបស់សហគមន៍ សម្រាប់រៀបចំផែនការបោសសម្អាតប្រចាំឆ្នាំ។ |
| សំណល់ជាតិផ្ទុះពីសង្គ្រាម | សំដៅលើយុទ្ធភណ្ឌមិនទាន់ផ្ទុះ និងយុទ្ធភណ្ឌដែលបោះបង់ចោល រួមទាំងគ្រាប់បែកចង្កោម ដោយមិនរាប់បញ្ចូលគ្រាប់មីន។ |